ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

## មាតិកា

### I- ខុទ្ទកាល័យព្រះមហាក្សត្រ

#### ព្រះរាជក្រម

១០-៨-២០០១ -ព្រះរាជក្រម នស//រកម/០៨០១/១២ ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយកាលនៃកម្ពុជាប្រជាធិបតេយ្យ ២១៤៩

#### ២- ព្រះរាជក្រឹត្យ

០៩-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៦៧ ស្ដីពីការតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ កុល ឆ័ត** ជាទីប្រឹក្សាប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ២១៧១

១០-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៨ ស្ដីពីការតែងតាំងឯកឧត្ដម **ឈឹម សៀកឡេង** ជាទីប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ២១៧២

១០-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៦៩ ស្ដីពីការបន្ថយរយៈពេលរងទោសឱ្យទណ្ឌិត ២១៧៣

១០-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៧០ ស្ដីពីការបន្ថយរយៈពេលរងទោសឱ្យទណ្ឌិត ២១៨០

១០-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៧១ ស្ដីពីការតែងតាំងៈ

១-ឯកឧត្ដម **ចំនួ តានី** ជាអគ្គលេខាធិការនៃអាជ្ញាធរសវនកម្មជាតិ មានឋានៈ ស្មើរដ្ឋលេខាធិការ

២-ឯកឧត្ដម **លុក ញឹម** ជាអគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ មានឋានៈ ស្មើអនុរដ្ឋលេខាធិការ ២១៨៦

១០-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៧២ ស្ដីពីការបញ្ឈប់ឯកឧត្ដម **កែវ ឡុងឌី** ពីតំណែងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ២១៨៧

១០-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ០៨០១/២៧៣ ស្ដីពីការតែងតាំងឯកឧត្ដម **ម៉ៅ ឃី** ជានាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាលបន្ថែមលើមុខងារបច្ចុប្បន្ន ២១៨៨

### III - រាជរដ្ឋាភិបាល

#### ១-អនុក្រឹត្យ

០៩-៨-២០០១ - អនុក្រឹត្យ លេខ ៧៧ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មការអតីតយុទ្ធជនខេត្ត-ក្រុង ២១៨៩

០៩-៨-២០០១ - អនុក្រឹត្យ លេខ ៧៨ អនក្រ.បក ស្ដីពីការបង្កើតវិទ្យាស្ថាន វ៉ាន់ ជា ២១៩៤

១០-៨-២០០១ -អនុក្រឹត្យលេខ ៧៩អនក្រ.បក ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ២១៩៦

១០-៨-២០០១ - អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្ដីពីការរៀបចំនិងការគ្រប់គ្រងរមនីយដ្ឋានភ្នំព្រះរាជ ទ្រព្យ ២២០២

០៩-៨-២០០២ - អនុក្រឹត្យលេខ ៣៦៦ អនក្រ.តត ស្ដីពីការកែសំរួលសមាសភាពនៃក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ ២២១០

០៩-៨-២០០១ - អនុក្រឹត្យលេខ ៣៦៧ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ ប្រគេនព្រះសាសនសំវរៈ **អ៊ំ លឹមហេង** ២២១៣

០៩-៨-២០០១ - អនុក្រឹត្យលេខ ៣៦៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២២១៤

១៣-៨-២០០១ - អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្ដីពីការតែងតាំងលោក **ចៃណ ម៉េងអ៊ាង** ជាប្រធាននាយកដ្ឋានអង្គការអន្តរជាតិនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ២២១៥

១៥-៨-២០០១ - អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២១៦

១៥-៨-២០០១ - អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២២១៧

### ២_សេចក្ដីសំរេច

០៩-៨-២០០១ - សេចក្ដីសំរេចលេខ ៤៩ សសរ ស្ដីពីការប្រគល់សិទ្ធិចុះហត្ថលេខានៅក្នុងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ២២១៩

១០-៨-២០០១ - សេចក្ដីសំរេចលេខ ៥០ សសរ ស្ដីពីការបង្កើតលេខាធិការដ្ឋានរបស់ការិយាល័យ សន្តិសុខថ្នាក់កណ្ដាល ២២២៣

១៥-៨-២០០១ - សេចក្ដីសំរេចលេខ ៥១ សសរ ស្ដីពីការបង្កើតក្រុមការងារសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២២២៧

## III _ ការងារបណ្ដាក្រសួង

### ១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

០៩-៨-២០០១ -សេចក្ដីសំរេចលេខ ៣៩៤ សសរ.កសក ស្ដីពីការផ្លាស់ប្ដូរសមាសភាពមន្ត្រីរាជការក្នុងសេចក្ដីសំរេចលេខ ២១៧ សសរ.កសក ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៧ លេខ ២៥០ សសរ.កសក.ចត ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៨ និង លេខ ០៦១ សសរ.កសក.បុ. ចុះថ្ងៃទី១៣ កុម្ភៈ ឆ្នាំ ២០០១ ដើម្បីអនុវត្តគំរោងបង្កើនផលិតភាពកសិកម្មក្នុងក្របខ័ណ្ឌធនាគារពិភពលោក ២២២៩

## ២. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១០-៨-២០០១ -ប្រកាសលេខ ៥៣១ ឧរថ.ធរ.ប្រក ស្តីពីការអនុញ្ញាតអោយលោកស្រី **នាក់ យន់** មានអាស័យដ្ឋានភូមិ ព្រៃថ្នង ឃុំព្រៃថ្នង ស្រុកកំពត ខេត្តកំពតធ្វើអាជីវកម្មថ្ម សំរាប់ដុតធ្វើកំបោសរ និងថ្មដុស ថ្មលាង នៅតំបន់ភ្នំដុប ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ២២៣២

## ១. ធនាគារជាតិនៃកម្ពុជា

១៤-៨-២០០១ -ប្រកាសលេខ ធ.៧.០១.១១៥ ប្រក ស្តីពីការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ ២២៣៤

## ៤. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១០-៨-២០០១ -ប្រកាសលេខ ១២៥ ប្រក បបប/២០០១ ស្តីពីការបង្កើតគណៈកម្មការមេ ប្រយោគ ដើម្បីដឹកនាំ គ្រប់គ្រងគណៈកម្មការក្នុងការប្រឡងជ្រើសរើសនិស្សិត សិស្សឱ្យចូលក្របខ័ណ្ឌក្រសួងយុត្តិធម៌និងបូកសរុបវាយតម្លៃប្រកាសលទ្ធផលប្រឡង ២២៣៦

១០-៨-២០០១ -ប្រកាសលេខ ១២៦ ប្រក បបប/២០០១ ស្តីពីការបង្កើតអនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ និងអនុគណៈកម្មការហិរញ្ញវត្ថុ ក្នុងការប្រឡងជ្រើសរើសនិស្សិត សិស្សឱ្យចូលក្របខ័ណ្ឌក្រសួងយុត្តិធម៌ ២២៣៩

នស/រកម/០៨០១/១២

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ក្រឹត្យលេខ ០៦ក្រ. ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ លើកលែងតែបទប្បញ្ញត្តិទាំងឡាយដែលបានចែងថា "...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី " ដែលជាទោសសម្លាប់ក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលត្រូវបានបង្កុលក្នុងមាត្រា ៣នៃច្បាប់នេះ

មាត្រា ៣ នេះ ត្រូវបានធ្វើវិសោធនកម្មតាមសំណើរបស់រាជរដ្ឋាភិបាល ក្នុងលិខិតលេខ ១០៤ សស. កបច. ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១ ដោយទទួលបានការអនុម័តពីរដ្ឋសភាក្នុងថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំលើកទី ៦ នីតិកាលទី ២ និងការអនុម័តយល់ស្រប ពីព្រឹទ្ធសភានៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញក្នុង សេចក្តីសម្រេចរបស់ខ្លួន លេខ០៤៧/០០៥/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ។

ច្បាប់នេះ មានសេចក្តីទាំងស្រុងដូចតទៅ ÷

# ច្បាប់

## ស្តីពី

# ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។

## ជំពូកទី ២

## សមត្ថកិច្ច

**មាត្រា ២.-**

ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ពោលគឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹង អំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។

មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថា "ជនសង្ស័យ" ។

**មាត្រា ៣.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ :

- មនុស្សឃាត មាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និងមាត្រា ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការវាយប្រហារលើសាសនា មាត្រា ២០៩ និងមាត្រា ២១០ ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបាន

ពន្យារពេលបន្ថែម ២០ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩. ៥០០. ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ត្រូវកំណត់ជាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

### មាត្រា ៤.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាលគឺជាអំពើមួយ ក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា ៖

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
- ការធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ ស្មារតីបញ្ញាសមាជិកនៃក្រុម
- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់
- បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
- ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក
- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត ។

បទល្មើសខាងក្រោមត្រូវផ្តន្ទាទោសដូចបទល្មើសខាងលើដែរ ៖

- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

### មាត្រា ៥.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយដូចជា ÷

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត ។

មាត្រា ៦.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឱ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដូចជាអំពើប្រឆាំងមនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ÷

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

- ការនិរទេស ការជន្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ៧.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

**មាត្រា ៨.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូត ហើយដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

## ជំពូកទី ៣

## សមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៩.-**

សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូប ដែលរួមមានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធាន ចូលរួមព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ ។

សាលាឧទ្ធរណ៍ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំពីររូប ដែលរួមមានចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ ប្រធានចូលរួមព្រមទាំងមាន សហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាឧទ្ធរណ៍នេះ ។

តុលាការកំពូលជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំបួនរូប ដែលរួមមាន ចៅក្រមខ្មែរប្រាំរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបួនរូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួមព្រមទាំងមាន សហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។

# ជំពូកទី ៤
# ការតែងតាំងចៅក្រមជម្រះក្តី

## មាត្រា ១០.-

ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀងនិងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ ។

ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

## មាត្រា ១១.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចដប់ពីររូប ឱ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនិងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរ នូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើ តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមបម្រុងខ្មែរត្រូវជំនួស ចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិ នៅពេលដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ ។ ចៅក្រមជម្រះក្តីទាំងនេះ អាចបន្តបំពេញការងារប្រចាំថ្ងៃ នៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិច បុគ្គលប្រាំបួនរូបដែលមានសញ្ជាតិបរទេស ឱ្យធ្វើជាចៅក្រមជម្រះក្តីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេស ដែលមានចំនួនយ៉ាងតិចដប់ពីររូប ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិប្រាំបួនរូប និងចៅក្រមបម្រុងយ៉ាងតិចបីរូបពីក្នុងបញ្ជីឈ្មោះនោះ ។ បន្ថែមពីលើចៅក្រមបរទេសដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញអាចចាត់តាំងតាមករណីនីមួយៗនូវចៅក្រមបម្រុងមួយរូបឬច្រើនរូប ដែលត្រូវបានជ្រើសរើសរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឱ្យជំនួសចៅក្រមបរទេសប្រសិនបើចៅក្រមរូបនោះ ពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន ។

**មាត្រា ១២.-**

ចៅក្រមជម្រះក្តីទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ចៅក្រមជម្រះក្តីមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

**មាត្រា ១៣.-**

ចៅក្រមជម្រះក្តីត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការនិងអ្នកជំនួយការច្បាប់ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ ក្នុងករណីចាំបាច់និងត្រូវមានការយល់ព្រមដោយមតិភាគច្រើនពីចៅក្រមខ្មែរ ក្នុងការជួលបុគ្គលិកដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ។ ចំនួនបុគ្គលិកនិងអ្នកជំនួយការច្បាប់ត្រូវជ្រើសរើសទៅតាមសមាមាត្រ នៃចៅក្រមខ្មែរ និងចៅក្រមបរទេស ។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬ ជនជាតិខ្មែរដទៃទៀតដែលមានសមត្ថភាព ក្នុងករណីចាំបាច់ ។

## ជំពូកទី ៥

## ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ១៤.-**

១. ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ ប្រសិនបើភាពឯកច្ឆ័ន្ទ នេះពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ក- ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងតម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូប យ៉ាងតិច ។

ខ- ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូប យ៉ាងតិច ។

គ- ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូល តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំមួយរូប យ៉ាងតិច ។

២. នៅពេលដែលពុំមានភាពឯកច្ឆន្ទនោះទេ សេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើន និងមតិភាគតិច ។

**មាត្រា ១៥.-**

ប្រធានត្រូវធ្វើការកោះប្រជុំចៅក្រមដែលបានតែងតាំង នៅក្នុងរយៈពេលសមស្របដើម្បីដំណើរការងារនៃអង្គជំនុំជម្រះវិសាមញ្ញ ។

## ជំពូកទី ៦
## សហព្រះរាជអាជ្ញា

**មាត្រា ១៦.-**

រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញគឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀត ជាបរទេស ដែលហៅថា "សហព្រះរាជអាជ្ញា" ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។

**មាត្រា ១៧.-**

សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្តឹងឧទ្ធរណ៍ ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

សហព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍មានសិទ្ធិប្តឹងសាទុក្ខ ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ ។

**មាត្រា ១៨.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួន តាមតម្រូវការពីក្របខ័ណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។

ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិ នៅពេលដែលព្រះរាជអាជ្ញានោះអវត្តមាន ឬមានធុរៈ ។

ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ព្រះរាជអាជ្ញាបរទេសមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់ទាំងបីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូប ជាសហព្រះរាជអាជ្ញាបរទេស ជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូប និងព្រះរាជអាជ្ញាបម្រុងមួយរូប ចេញពីបញ្ជីបេក្ខជននេះ ។

**មាត្រា ១៩.-**

សហព្រះរាជអាជ្ញាត្រូវបានជ្រើសតាំងក្នុងចំណោមបុគ្គលទាំងឡាយដែលបានជ្រើសតាំងតាមនីតិវិធីនៃការជ្រើសតាំងព្រះរាជអាជ្ញា ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ សុចរិតនិងមានបទពិសោធន៍ជំនាញ ក្នុងការធ្វើការស៊ើបអង្កេត និងក្នុងការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌ ។

សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២០.-**

សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើចាំបាច់ ហើយនីតិដែលនៅជាធរមាន មានការខ្វះចន្លោះ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញាឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយល័ក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នារបស់គេ ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរ បីរូបត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិងចៅក្រមបរទេសពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១០ នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ប្រធានការិយាល័យរដ្ឋបាល ត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅ

ក្រុមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើន ដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត ។

ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

មាត្រា ២១.-

សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ព្រះរាជអាជ្ញាមួយរូបៗ ត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុង ។

មាត្រា ២២.-

សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេសត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិ ជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែង សម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្មាសន៍ ក្នុងករណីចាំបាច់និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរ ក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ ។ ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរ និងព្រះរាជអាជ្ញាបរទេស ។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋឬជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាព ក្នុងករណីចាំបាច់ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

## ជំពូកទី ៧
## អំពីការស៊ើបអង្កេត

**មាត្រា ២៣.-**

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើចាំបាច់ ហើយនីតិវិធីនៅជាធរមាននោះមានការខ្វះចន្លោះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម ៖

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម ៖

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ អំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នា ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី ៣ រួចមក ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមាន ពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយ សេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៅទៀត ។

សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃពតិមាន ដែលទទួលបានពីស្ថាប័ននានា រួមមាន រដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលជាដើម ។

សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ខានមិនបាន សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសុំឱ្យសហព្រះរាជអាជ្ញាធ្វើការសាកសួរសាក្សីបន្ថែមបាន ។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថា សមស្រប និងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

**មាត្រា ២៤.-**

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដោយខានមិនបាន ហើយដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីរ៉ាប់រងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសា ដែលជនសង្ស័យនិយាយ និងយល់បាន ។

**មាត្រា ២៥.-**

សហចៅក្រមស៊ើបអង្កេតត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ សុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ។ សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួនហើយមិនត្រូវទទួល ឬ ស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២៦.-**

សហចៅក្រមស៊ើបអង្កេតខ្មែរ និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ ។

ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ ។ ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ចៅក្រមស៊ើបអង្កេតបរទេសត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់រយៈពេលនៃការស៊ើបអង្កេត បន្ទាប់ពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាចៅក្រមស៊ើបអង្កេតបរទេស ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិមួយរូប និងបម្រុងមួយរូបពីបញ្ជីបេក្ខជននេះ ។

**មាត្រា ២៧.-**

ចៅក្រមស៊ើបអង្កេតទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និង លក្ខខណ្ឌការងារស្មើៗគ្នា ។

ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត ។

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុង ។

**មាត្រា ២៨.-**

សហចៅក្រមស៊ើបអង្កេតមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តតាមស្មារតីនៃបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

## ជំពូកទី ៨
## ការទទួលខុសត្រូវជាបុគ្គល

**មាត្រា ២៩.-**

ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ ។

តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ ។

ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជានិងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹងនិងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ ។

ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ។

## ជំពូកទី ៩
## ការិយាល័យរដ្ឋបាល

**មាត្រា ៣០.-**

បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ ។

ការិយាល័យនេះមានប្រធានខ្មែរមួយរូប អនុប្រធានបរទេសមួយរូប និងបុគ្គលិកមួយចំនួនតាមតម្រូវការជាក់ស្តែង ។

**មាត្រា ៣១.-**

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល ២ ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាលមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល ។

ប្រធានការិយាល័យរដ្ឋបាល ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាលតុលាការ មានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈ និង ស្មារតីខ្ពស់ និងសុចរិត ។

អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាល ត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ ដូចដែលបានតម្រូវឱ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេតការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ។ អនុប្រធានការិយាល័យរដ្ឋបាល ត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិជាជំនួយការ តាមតម្រូវការជាក់ស្តែង ។

បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាល ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ប្រធានការិយាល័យ ។ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល ។

បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាព ក្នុងករណីចាំបាច់ ។

**មាត្រា ៣២.-**

បុគ្គលិកទាំងអស់ដែលមានភារកិច្ចជួយជាជំនួយការដល់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និង ការិយាល័យរដ្ឋបាល ទទួលបាននូវលក្ខខណ្ឌការងារដូចៗគ្នា ទៅតាមលំដាប់ថ្នាក់នៃ អង្គជំនុំជំរះវិសាមញ្ញនីមួយៗ ។

## ជំពូកទី ១០
## កិច្ចដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៣៣.-**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ បើជាការចាំបាច់ ហើយនីតិវិធីដែលនៅជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួនដោយស្ម័គ្រចិត្ត និងក្នុងការចាត់ការឱ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដែលរួមមានកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាឱ្យជនដែលត្រូវបានចោទប្រកាន់ ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។

**មាត្រា ៣៤.-**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ។

**មាត្រា ៣៥.-**

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា ដូចខាងក្រោម :

ក/ ទទួលពត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ/ មានពេលវេលាដើម្បីរៀបចំខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន

គ/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

ឃ/ ត្រូវបានការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី របស់ខ្លួន

ង/ ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានិងភ័ស្តុតាងដាក់បន្ទុកដែរ

ច/ មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ

ឆ/ មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស ។

**មាត្រា ៣៦.-**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ របស់ជនរងគ្រោះ ឬរបស់សហព្រះរាជអាជ្ញា ក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការភាន់ច្រឡំទៅលើអង្គហេតុ
- ការភាន់ច្រឡំទៅលើអង្គច្បាប់ ។

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ពិនិត្យមើលវិញនូវការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ។ អង្គជំនុំជម្រះវិសាមញ្ញនេះអាចសម្រេចសេចក្តីស្រប ឬផ្ទុយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ឬកែប្រែសេចក្តីសម្រេចនេះបាន ។ ក្នុងករណីនេះ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ ត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។ ប្រសិនបើជាការចាំបាច់ ហើយបើនីតិវិធីដែលនៅជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

**មាត្រា ៣៧.-**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះនិងរបស់សហព្រះរាជអាជ្ញា ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ ក្នុងករណីនេះ តុលាការកំពូលពិនិត្យសម្រេចជាចុងក្រោយ ទាំងអង្គហេតុ ទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍វិញទេ ។

## ជំពូកទី ១១

## ទោសបញ្ញត្តិ

**មាត្រា ៣៨.-**

ទណ្ឌកម្មទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ ។

មាត្រា ៣៩.-

ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារ ពី៥ឆ្នាំ រហូតដល់មួយជីវិត ។

ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ ។

## ជំពូកទី ១២

## ការលើកលែងទោសនិងការអនុគ្រោះទោស

មាត្រា ៤០.-

រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះបានឡើយ ។

## ជំពូកទី ១៣

## ឋានៈ សិទ្ធិ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

មាត្រា ៤១.-

ចៅក្រមបរទេស សហចៅក្រមស៊ើបអង្កេតបរទេស សហព្រះរាជអាជ្ញាបរទេសនិងអនុប្រធានការិយាល័យរដ្ឋបាល រួមបញ្ចូលទាំងក្រុមគ្រួសាររបស់ពួកគេ ដែលជាផ្នែកនៃគ្រួសាររបស់ពួកគេ ត្រូវមានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងអស់ ការរួចពន្ធនិងគ្រឿងបរិក្ខារប្រើប្រាស់ ដូចដែលផ្តល់ជូនដល់ភ្នាក់ងារការទូត ដោយអនុលោមតាមអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូតនាឆ្នាំ ១៩៦១ ។ មន្ត្រីទាំងអស់នេះត្រូវបានរួចពីការជាប់ពន្ធលើប្រាក់បៀវត្សរ៍បរិលាភនិងវិភាជន៍ របស់ពួកគេនៅក្នុងប្រទេសកម្ពុជា ។

មាត្រា ៤២.-

១- បុគ្គលិកខ្មែរត្រូវបានផ្តល់អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ ។

២-បុគ្គលិកបរទេសត្រូវបានផ្តល់បន្ថែមនូវ :

ក- អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញ ក្នុងតំណែងផ្លូវការរបស់ពួកគេ ។

ខ- អភ័យឯកសិទ្ធិឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស វិភាជន៍ និងបរិលាភដែលបើកជូន ពួកគេ ដោយបណ្តារដ្ឋាភិបាលដែលចូលរួមវិភាគទាន ចំពោះមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

គ- អភ័យឯកសិទ្ធិឱ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍ ។

ឃ- សិទ្ធិនាំចូលដោយរួចពន្ធអាករ គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ លើកលែងតែការចំណាយសម្រាប់សេវាកម្ម នៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូង នៅប្រទេសកម្ពុជា ។

៣- មេធាវីរបស់ជនសង្ស័យ ឬ ជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវី ដោយអង្គជំនុំជម្រះមិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារ ដោយសេរី និងឯករាជ្យ របស់ខ្លួននៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

ជាពិសេស មេធាវីត្រូវបានផ្តល់នូវៈ

ក- អភ័យឯកសិទ្ធិឱ្យរួចផុតពីការចាប់ ឬឃុំខ្លួននិងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ

ខ- ភាពមិនអាចរំលោភបំពានបាន នូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវី របស់ជនសង្ស័យ ឬជនជាប់ចោទ

គ- អភ័យឯកសិទ្ធិឱ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាព ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី ។

៤- បណ្ណសារដ្ឋាននៃតុលាការនិងជាទូទៅឯកសារនិងសម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់តុលាការ ឬ ប្រើប្រាស់ដោយតុលាការ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រ កម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយគឺមិនអាចត្រូវបានរំលោភបំពានបាន ក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។

## ជំពូកទី ១៤
## ទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៤៣.-**

អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល មានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។

## ជំពូកទី ១៥
## ការចំណាយ

**មាត្រា ៤៤.-**

ការចំណាយ និងប្រាក់បៀវត្ស របស់អង្គជំនុំជម្រះវិសាមញ្ញមាន ៖

១- ការចំណាយនិងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្តីនិងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។

២- ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

៣- ប្រាក់បៀវត្សរបស់មន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស សហចៅក្រមជម្រះក្តីបរទេស ចៅក្រមស៊ើបអង្កេតបរទេស និង សហព្រះរាជអាជ្ញាបរទេស ជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមក តាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤- មេធាវីការពារក្តី អាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។

៥- ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

## ជំពូកទី ១៦
## ភាសាការងារ

**មាត្រា ៤៥.-**

ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញគឺភាសាខ្មែរ ហើយបកប្រែជាភាសាអង់គ្លេស ភាសាបារាំង និង រុស្ស៊ី ។

## ជំពូកទី ១៧
## ករណីគ្មានចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស

**មាត្រា ៤៦.-**

ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលានិងមិនរអាក់រអួល ក្នុងករណីដែលចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬបដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀតឱ្យបំពេញកន្លែងទំនេរ ក្នុងចំណោមបញ្ជីបេក្ខជនបរទេស ដែលមានចែងក្នុងមាត្រា ១១, ១៨ និងមាត្រា ២៦ នៃច្បាប់នេះ ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ កន្លែងទំនេរទាំងនោះ ត្រូវបំពេញបន្ថែមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាល នៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត ។

បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសចូលរួម ក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឱ្យបំពេញតំណែងទំនេរនេះទេ នៅពេលនោះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស ។

## ជំពូកទី ១៨
## អត្ថិភាពនៃអង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៤៧.-**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះ បានចប់ជាស្ថាពរ ។

## ជំពូកទី ១៩
## អវសានប្បញ្ញត្តិ

**មាត្រា ៤៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ហត្ថលេខា**

**សុខ អាន**

លេខ :១៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០១

**រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ៥១៦ រស ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០១
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា ១**.- តែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ កុលធំត** ជាទីប្រឹក្សាប្រធានរដ្ឋសភា ទទួលបន្ទុកកិច្ចការវប្បធម៌វិចិត្រសិល្បៈ និងសំណង់នគរូបនីយកម្ម ដែលមានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២**.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣**.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០១

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៨

យើង

ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម **ឈឹម សៀកឡេង**

ជា

ឧត្តមប្រឹក្សាផ្ទាល់ របស់ព្រះមហាក្សត្រ

នៃ

ព្រះរាជាណាចក្រកម្ពុជា

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ

ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០១

លេខៈ ១៩២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែ សី៣ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៨៨

## ត្រាស់បង្គាប់

<u>មាត្រា</u> ១ ៖ ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ ឱ្យទណ្ឌិតចំនួន ៩នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១- ទណ្ឌិតឈ្មោះ ហួន ហាក់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៤-០៥-៨៩ របស់តុលាការខេត្ត កំពង់ធំ ។

២- ទណ្ឌិតឈ្មោះ ឡាក់ ឌុយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ០៩-០៧-៩២ របស់តុលាការ ខេត្តកំពង់ធំ ។

៣- ទណ្ឌិតឈ្មោះ ឯក សាគុណ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៥-០៩-៩១ របស់តុលាការខេត្ត ស្វាយរៀង ។

៤- ទណ្ឌិតឈ្មោះ ណែម ណាយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ០៩-០៦-៩២ របស់តុលាការខេត្ត សៀមរាប ។/.

៥_ ទណ្ឌិតឈ្មោះ **ឃៀង សុខា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំតាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ១០_៣_៩៤ របស់តុលាការខេត្តសៀមរាប។

៦_ ទណ្ឌិតឈ្មោះ **មួង ឈឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំតាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ១០_៣_៩៤ របស់តុលាការខេត្តសៀមរាប។

៧_ ទណ្ឌិតឈ្មោះ **សុខ ដឿង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំតាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ២១_៦_៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៨_ ទណ្ឌិតឈ្មោះ **អំ ប៉្រចឆាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១_១២_៩៥ របស់តុលាការខេត្តក្រចេះ ។

៩_ ទណ្ឌិតឈ្មោះ **អំ ប៉្រចអាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១_១២_៩៥ របស់តុលាការខេត្តក្រចេះ ។

**<u>មាត្រា</u> ២** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ អោយទណ្ឌិតចំនួន ១៨នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១_ ទណ្ឌិតឈ្មោះ **សេក លន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ១០_០៧_៩២ របស់តុលាការខេត្តកំពង់ធំ ។

២_ ទណ្ឌិតឈ្មោះ **ចាង ណៃ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២៦_០៤_៩៥ របស់តុលាការខេត្តកំពង់ធំ ។

៣_ ទណ្ឌិតឈ្មោះ **អ៊ុច ជុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំតាមអំណាចសាលក្រមលេខ ១៣ចុះថ្ងៃទី ២៥_១២_៩២ របស់តុលាការខេត្តស្វាយរៀង ។

៤_ ទណ្ឌិតឈ្មោះ **ទេព សុផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ចុះថ្ងៃទី ២៩_០៤_៩៥ របស់តុលាការខេត្តស្វាយរៀង ។

៥_ ទណ្ឌិតឈ្មោះ **អៀង ស៊ាប** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ចុះថ្ងៃទី ២៩_១០_៩១ របស់តុលាការខេត្តស្វាយរៀង ។

៦_ ទណ្ឌិតឈ្មោះ **យន់ យឹង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ ចុះថ្ងៃទី ២០_១០_៩៧ របស់តុលាការខេត្តសៀមរាប។

៧_ ទណ្ឌិតឈ្មោះ **មាស ពៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ៣២០ ចុះថ្ងៃទី ០៣_១២_៩៩ របស់សាលាឧទ្ធរណ៍ ។

៨_ ទណ្ឌិតឈ្មោះ **ហុង ពៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ

កំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ២៨_១២_៩៥ របស់តុលាការខេត្តកំពង់ស្ពឺ។

៩_ ទណ្ឌិតឈ្មោះ **ប្រឹម ស្រេង**ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ០៧_៣_៩៥ របស់តុលាការខេត្តព្រៃវែង។

១០_ ទណ្ឌិតឈ្មោះ **គាត ឆេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៥_៤_៩៥ របស់តុលាការខេត្តព្រៃវែង។

១១_ ទណ្ឌិតឈ្មោះ **ឆេង ម៉េន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ២៦_៨_៩៤ របស់តុលាការខេត្តព្រៃវែង។

១២_ ទណ្ឌិតឈ្មោះ **ជុំ ឆាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ២៥_៧_៩៥ របស់តុលាការខេត្តក្រចេះ ។

១៣_ ទណ្ឌិតឈ្មោះ **ស៊ុំ ម៉ៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ២៣_០២_៩៦ របស់តុលាការខេត្តក្រចេះ ។

១៤_ ទណ្ឌិតឈ្មោះ **ហែន រ៉ូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ០៨_០៤_៩៦ របស់តុលាការខេត្តក្រចេះ ។

១៥_ ទណ្ឌិតឈ្មោះ **ឡាយ អ៊ិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១១_០៦_៩៦ របស់តុលាការខេត្តក្រចេះ ។

១៦_ ទណ្ឌិតឈ្មោះ **ឃ្លាត សារឿន**ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៣_០៤_៩៨ របស់តុលាការខេត្តក្រចេះ ។

១៧_ ទណ្ឌិតឈ្មោះ **អៀម ខោល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ០២_០៩_៩៧ របស់តុលាការខេត្តក្រចេះ ។

១៨_ ទណ្ឌិតឈ្មោះ **ឃិន គាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ០២_០៩_៩៧ របស់តុលាការខេត្តក្រចេះ ។

**មាត្រា ៣** ៖ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ អោយទណ្ឌិតចំនួន ២៩នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១_ ទណ្ឌិតឈ្មោះ **ដួង លឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ចុះថ្ងៃទី ២៤_០៥_២០០០ របស់តុលាការខេត្តកំពង់ធំ ។

២_ ទណ្ឌិតឈ្មោះ **លុយ ឆាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ២២_០៨_៩៥ របស់តុលាការខេត្តកំពង់ធំ ។

៣_ ទណ្ឌិតឈ្មោះ ឯម ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំតាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ៣០_០៦_៩៨ របស់តុលាការខេត្តកំពង់ធំ ។

៤_ ទណ្ឌិតឈ្មោះ ឌុច គឹមសត់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំតាមអំណាចសាលក្រមលេខ ១៨ចុះថ្ងៃទី ២៨_០៣_៩៦ របស់តុលាការខេត្តកំពង់ធំ ។

៥_ ទណ្ឌិតឈ្មោះ សាន់ ដារ៉ា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំតាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ១៥_៩_២០០០ របស់តុលាការខេត្តស្វាយរៀង ។

៦_ ទណ្ឌិតឈ្មោះ សុខ ថ៊ាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ០៩_២_២០០០ របស់តុលាខេត្តសៀមរាប។

៧_ ទណ្ឌិតឈ្មោះ សៅ លីក ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំតាមអំណាចសាលក្រមលេខ ១៥ចុះថ្ងៃទី ០៩_០២_២០០០ របស់តុលាការខេត្តសៀមរាប ។

៨_ ទណ្ឌិតឈ្មោះ ហូ ស៊ីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២១១ ចុះថ្ងៃទី ១២_០៨_៩៧ របស់តុលាការខេត្តសៀមរាប។

៩_ ទណ្ឌិតឈ្មោះ សេង សុត្រ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំតាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៣_០៤_៩៨ របស់តុលាការខេត្តសៀមរាប ។

១០_ ទណ្ឌិតឈ្មោះ ជ័យ កែវចិរះ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ចុះថ្ងៃទី ២៨_១១_៩៦ របស់តុលាការខេត្តកោះកុង ។

១១_ ទណ្ឌិតឈ្មោះ សៅ ប៊ុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ចុះថ្ងៃទី ១៩_០៩_៩៧ របស់តុលាការខេត្តកោះកុង ។

១២_ ទណ្ឌិតឈ្មោះ ឈុំ វណ្ណា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំតាមអំណាចសាលក្រមលេខ ៣ "ឃ" ចុះថ្ងៃទី ១១_២_២០០០ របស់តុលាការក្រុងភ្នំពេញ ។

១៣_ ទណ្ឌិតឈ្មោះ កែវ រិទ្ធ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំតាមអំណាចសាលក្រមលេខ ១២ "ឈ" ចុះថ្ងៃទី២៣_៣_២០០០ របស់តុលាការក្រុងភ្នំពេញ។

១៤_ ទណ្ឌិតឈ្មោះ ឈុន ចិត្រា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ "ដ" ចុះថ្ងៃទី ៦_៤_២០០០ របស់តុលាការក្រុងភ្នំពេញ។

១៥_ ទណ្ឌិតឈ្មោះ ម៉ែន ស៊ីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ "ដ" ចុះថ្ងៃទី ៦_៤_២០០០ របស់តុលាការក្រុងភ្នំពេញ ។

១៦_ ទណ្ឌិតឈ្មោះ មូល ម៉េត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ "ដ" ចុះថ្ងៃទី ៦_៤_២០០០ របស់តុលាការក្រុងភ្នំពេញ ។

១៧_ ទណ្ឌិតឈ្មោះ ឡេង ឡាំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៧ឆ្នាំ តាមអំណាចសាលដីកាលេខ ៣២០ ចុះថ្ងៃទី ៣_១២_៩៩ របស់សាលាឧទ្ធរណ៍ ។

១៨_ ទណ្ឌិតឈ្មោះញ៉ែម យ៉ុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ២១ ចុះថ្ងៃទី ១៥_៣_២០០០ របស់តុលាការខេត្តព្រៃវែង ។

១៩_ ទណ្ឌិតឈ្មោះ អ៊ុន សុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ៥៥ ចុះថ្ងៃទី ២២_៦_២០០០ របស់តុលាការខេត្តព្រៃវែង ។

២០_ ទណ្ឌិតឈ្មោះ ចាន់ ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ៤៩ ចុះថ្ងៃទី ២១_៧_៩៤ របស់តុលាការខេត្តព្រៃវែង ។

២១_ ទណ្ឌិតឈ្មោះ ស៊ិន រ៉ុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ៩៣ ចុះថ្ងៃទី ០១_១២_៩៩ របស់តុលាការខេត្តព្រៃវែង ។

២២_ ទណ្ឌិតឈ្មោះ អ៊ិន រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ៥៦ ចុះថ្ងៃទី ០២_៨_៩៩ របស់តុលាការខេត្តព្រៃវែង ។

២៣_ ទណ្ឌិតឈ្មោះ ឆៅ ជឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៤២ខែ តាមអំណាចសាលក្រមលេខ៤០ ចុះថ្ងៃទី ០១_៧_៩៨ របស់តុលាការខេត្តព្រៃវែង ។

២៤_ ទណ្ឌិតឈ្មោះ មាស អៀត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ៣៥ ចុះថ្ងៃទី ០២_៦_៩៨ របស់តុលាការខេត្តព្រៃវែង ។

២៥_ ទណ្ឌិតឈ្មោះ យោ តឿ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ១៥ ចុះថ្ងៃទី ២_៣_២០០០ របស់តុលាការខេត្តព្រៃវែង ។

២៦_ ទណ្ឌិតឈ្មោះ សួន ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ០៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ ចុះថ្ងៃទី ០៥_០៨_៩៦ របស់តុលាការខេត្តក្រចេះ ។

២៧_ ទណ្ឌិតឈ្មោះ ព្រាប ឡេត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ០៧ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ០៦_៥_៩៧ របស់តុលាការខេត្តក្រចេះ។

២៨_ ទណ្ឌិតឈ្មោះ ញ៉ៀប សុខា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ០៧ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ០៦_៥_៩៧ របស់តុលាការខេត្តក្រចេះ។

២៩_ ទណ្ឌិតឈ្មោះ កែវ ឫទ្ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ
កំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ "ក" ចុះថ្ងៃទី ២៤_០៥_៩៩ របស់តុលាការក្រុងភ្នំពេញ ។

**មាត្រា ៤** : ត្រូវបានលើកលែងទោសអោយទណ្ឌិតចំនួន ១៦នាក់ ដែលបានខិតខំកែប្រែខ្លួន
បានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១_ ទណ្ឌិតឈ្មោះ អ៊ុច សៀម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំតាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ៣១_០៥_៩៥ និងសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ២៥_០៧_៩៥ របស់តុលាការខេត្តកំពង់ធំ ។

២_ ទណ្ឌិតឈ្មោះ ម៉ាន រ៉ី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ២៣_០៦_៩៥ របស់តុលាការខេត្តកំពង់ធំ ។

៣_ ទណ្ឌិតឈ្មោះ តើន តិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៧_០៣_៩៩ របស់តុលាការខេត្តមណ្ឌលគីរី ។

៤_ ទណ្ឌិតឈ្មោះ ទ្រើស រ៉យេ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ០៦ខែ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ១២_០៥_២០០០ របស់តុលាការខេត្តមណ្ឌលគីរី ។

៥_ ទណ្ឌិតឈ្មោះ គាត ស្រ៊ន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ "យ" ចុះថ្ងៃទី ២៣_០៨_៩៥ របស់តុលាការខេត្តកំពង់ចាម ។

៦_ ទណ្ឌិតឈ្មោះ ណែម អ៊ី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៤ ឆ្នាំតាមអំណាចសាលក្រមលេខ ០៩ចុះថ្ងៃទី ១៦_០៥_៩១របស់តុលាការខេត្តសៀមរាប។

៧_ ទណ្ឌិតឈ្មោះ ខាន់ អូនហៅស៊ីថាដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំតាមអំណាចសាលដីកាលេខ ១៨៥ចុះថ្ងៃទី ២៨_០៧_២០០០របស់សាលាឧទ្ធរណ៍។

៨_ ទណ្ឌិតឈ្មោះ ជា វណ្ណា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលដីកាលេខ ១៨៥ចុះថ្ងៃទី ២៨_០៧_២០០០ របស់សាលាឧទ្ធរណ៍។

៩_ ទណ្ឌិតឈ្មោះ ខ្សៀង យ៉ាំងធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ "ង" ចុះថ្ងៃទី ១០_២_៩៥ របស់តុលាការក្រុងភ្នំពេញ ។

១០_ ទណ្ឌិតឈ្មោះ ផន សេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលដីកាលេខ ២៤ ចុះថ្ងៃទី ១៥_៨_៩៧ របស់តុលាការកំពូល ។

១១_ ទណ្ឌិតឈ្មោះ អ៊ុល គឹមហុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ០១_០៤_៩៩ របស់តុលាការខេត្តក្រចេះ ។

១២_ ទណ្ឌិតឈ្មោះ ឌឹម សេក ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ...

កំណត់ ០៩ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ១៥_០៣_៩៤ របស់តុលាការខេត្តក្រចេះ ។

១៣_ ទណ្ឌិតឈ្មោះ គង់ រុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ ចុះថ្ងៃទី ១១_០៥_៩៩ របស់តុលាការខេត្តក្រចេះ ។

១៤_ ទណ្ឌិតឈ្មោះ សា អាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៨១ ចុះថ្ងៃទី ៦១_០៧_៩៩ របស់តុលាការខេត្តក្រចេះ ។

១៥_ ទណ្ឌិតឈ្មោះ ជា ស្លា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៩ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៦_០៣_៩៤ របស់តុលាការខេត្តក្រចេះ ។

១៦_ ទណ្ឌិតឈ្មោះសុខ ហោង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០១ឆ្នាំ តាមអំណាចសាលដីកាលេខ ៤១ ចុះថ្ងៃទី ០៩_០៨_២០០០ របស់តុលាការកំពូល ។

<u>មាត្រា</u> ៥ :_ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

<u>មាត្រា</u> ៦ :_ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេចជាស្ថាពរ ។ល។

ព្រះហស្តលេខា

នរោត្តម សីហនុ

នស: ១៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១

ភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

៙

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៨៨

## ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ អោយទណ្ឌិតចំនួន ៧នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ៖

១- ទណ្ឌិតឈ្មោះ ស៊ុំ តី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ ចុះថ្ងៃទី ២៧-០៨-៩៣ របស់តុលាការខេត្តកណ្តាល ។

២- ទណ្ឌិតឈ្មោះ កើត សារី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ២៧-១១-៩០ របស់តុលាការខេត្តស្វាយរៀង ។

៣- ទណ្ឌិតឈ្មោះ គីម សុខុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៣-០៧-៩១ របស់តុលាការខេត្តស្វាយរៀង ។

៤- ទណ្ឌិតឈ្មោះ ជា សៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ២៣-០៧-៩១ របស់តុលាការខេត្តស្វាយរៀង ។

៥_ ទណ្ឌិតឈ្មោះ **លី ស៊ីន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ មួយជីវិត តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១៩_០៩_៨៥ របស់តុលាការខេត្តកំពត ។

៦_ ទណ្ឌិតឈ្មោះ **នក ហាប់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី ១៩_០៨_៩៤ របស់តុលាការខេត្តកំពត ។

៧_ ទណ្ឌិតឈ្មោះ **ឯម សារ៉េត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ០២_០២_៩៤ របស់តុលាការខេត្តកំពត ។

<u>មាត្រា</u> ២ :ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ អោយទណ្ឌិតចំនួន ៤ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ

១_ ទណ្ឌិតឈ្មោះ **ខាត់ ធា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ១៣៨ ចុះថ្ងៃទី ០២_០៧_៩៧ របស់សាលាឧទ្ធរណ៍ ។

២_ ទណ្ឌិតឈ្មោះ **ចាប ចូច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២"ក"ចុះថ្ងៃទី ១៦_៩_៩៦ របស់តុលាការខេត្តកណ្តាល ។

៣_ ទណ្ឌិតឈ្មោះ **ប្រាក់ ម៉ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ២៥_០៦_៩២ របស់តុលាការខេត្តស្វាយរៀង ។

៤_ ទណ្ឌិតឈ្មោះ **សុខ សាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ០៤_០៦_៩៤ របស់តុលាការខេត្តស្វាយរៀង ។

<u>មាត្រា</u> ៣ :ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ អោយទណ្ឌិតចំនួន ៤៩ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ

១_ ទណ្ឌិតឈ្មោះ **សឿង ឌុឌ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២១"រ"ចុះថ្ងៃទី ២៩_០៥_៩៦ របស់តុលាការខេត្តកណ្តាល ។

២_ ទណ្ឌិតឈ្មោះ **ពិន នឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២១"រ"ចុះថ្ងៃទី ២៩_០៥_៩៦ របស់តុលាការខេត្តកណ្តាល ។

៣_ ទណ្ឌិតឈ្មោះ **ចាន់ ពៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦"ព"ចុះថ្ងៃទី ២៥_០២_៩៧ របស់តុលាការខេត្តកណ្តាល ។

៤_ ទណ្ឌិតឈ្មោះ **មុំ ម៉ាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦"ព"ចុះថ្ងៃទី ២៥_០២_៩៧ របស់តុលាការខេត្តកណ្តាល ។

៥- ទណ្ឌិតឈ្មោះ សឿង ឈឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ "ភ" ចុះថ្ងៃទី ២៩-១០-៩៧ របស់តុលាការខេត្តកណ្តាល ។

៦- ទណ្ឌិតឈ្មោះ នៅ ឫទ្ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៣៩ "គ" ចុះថ្ងៃទី ០២-១២-៩៨ របស់តុលាការខេត្តកណ្តាល ។

៧- ទណ្ឌិតឈ្មោះ សុខ លី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ "គ" ចុះថ្ងៃទី ០២-១២-៩៨ របស់តុលាការខេត្តកណ្តាល ។

៨- ទណ្ឌិតឈ្មោះ សួន ពៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ភ" ចុះថ្ងៃទី ២៩-០៤-៩៩ របស់តុលាការខេត្តកណ្តាល ។

៩- ទណ្ឌិតឈ្មោះ ស៊ុំ ដឹង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "គ" ចុះថ្ងៃទី ២៣-៩-៩៩ របស់តុលាការខេត្តកណ្តាល ។

១០- ទណ្ឌិតឈ្មោះ លឹម ស្លាំង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ ៦ខែតាមអំណាចសាលក្រមលេខ ១៤ "ភ" ចុះថ្ងៃទី ២៩-៤-៩៩ របស់តុលាការខេត្តកណ្តាល ។

១១- ទណ្ឌិតឈ្មោះ ពៅ សារិទ្ធ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៦ "គ" ចុះថ្ងៃទី ២៩-៣-២០០០ របស់តុលាការខេត្តកណ្តាល ។

១២- ទណ្ឌិតឈ្មោះ កែ ហុងម៉ារ៉ូ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ "គ" ចុះថ្ងៃទី ២៩-៣-២០០០ របស់តុលាការខេត្តកណ្តាល ។

១៣- ទណ្ឌិតឈ្មោះ សៅ ជុំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ "គ" ចុះថ្ងៃទី ២៩-៣-២០០០ របស់តុលាការខេត្តកណ្តាល ។

១៤- ទណ្ឌិតឈ្មោះ ឆិត្យ ទិត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ "គ" ចុះថ្ងៃទី ២៩-៣-២០០០ របស់តុលាការខេត្តកណ្តាល ។

១៥- ទណ្ឌិតឈ្មោះ ឆឹម រ៉ាត្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ភ" ចុះថ្ងៃទី ៤-៥-២០០០ របស់តុលាការខេត្តកណ្តាល ។

១៦- ទណ្ឌិតឈ្មោះ សុខ តាំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ "ក" ចុះថ្ងៃទី ១៥-២-២០០០ របស់តុលាការខេត្តកណ្តាល ។

១៧- ទណ្ឌិតឈ្មោះ កាយ ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "ព" ចុះថ្ងៃទី ២៩-៦-២០០០ របស់តុលាការខេត្តកណ្តាល ។

១៨. ទណ្ឌិតឈ្មោះ ជា ឡូ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "ព" ចុះថ្ងៃទី ២៩.៦.២០០០ របស់តុលាការខេត្តកណ្តាល ។

១៩. ទណ្ឌិតឈ្មោះ ស៊ុន សារ៉ាវី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ "ព" ចុះថ្ងៃទី ១១.៧.២០០០ របស់តុលាការខេត្តកណ្តាល។

២០. ទណ្ឌិតឈ្មោះ យ៉េត ទុទ្ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ "ព" ចុះថ្ងៃទី ១១.៧.២០០០ របស់តុលាការខេត្តកណ្តាល។

២១. ទណ្ឌិតឈ្មោះ ពឹម សារុំម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលដីកាលេខ ១០ ចុះថ្ងៃទី ១៥.០១.៩៩ របស់សាលាឧទ្ធរណ៍ ។

២២. ទណ្ឌិតឈ្មោះ សួន សុហុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ "គ" ចុះថ្ងៃទី ២៦.១.២០០០ របស់តុលាការខេត្តកណ្តាល ។

២៣. ទណ្ឌិតឈ្មោះ ម៉ុន ថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ៩ខែ តាមអំណាចសាលក្រមលេខ ៣៦ "ភ" ចុះថ្ងៃទី ៧.៧.២០០០ របស់តុលាការខេត្តកណ្តាល ។

២៤. ទណ្ឌិតឈ្មោះ ជុំ ស៊ីដែន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ "ភ" ចុះថ្ងៃទី ១៩.៨.៩៩ របស់តុលាការខេត្តកណ្តាល ។

២៥. ទណ្ឌិតឈ្មោះ សៅ ចន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ "ភ" ចុះថ្ងៃទី ១៩.៨.៩៩ របស់តុលាការខេត្តកណ្តាល ។

២៦. ទណ្ឌិតឈ្មោះ ឃុន តារាម្យ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ "ព" ចុះថ្ងៃទី ១៣.៦.២០០០ របស់តុលាការខេត្តកណ្តាល។

២៧. ទណ្ឌិតឈ្មោះ សេង ធារ៉ា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ "ព" ចុះថ្ងៃទី ០៨.១២.៩៨ របស់តុលាការខេត្តកណ្តាល ។

២៨. ទណ្ឌិតឈ្មោះ ញែម ណារិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ "ព" ចុះថ្ងៃទី ០៨.១២.៩៨ របស់តុលាការខេត្តកណ្តាល ។

២៩. ទណ្ឌិតឈ្មោះ លាស់ សើរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "ភ" ចុះថ្ងៃទី ២១.៣.២០០០ របស់តុលាការខេត្តកណ្តាល ។

៣០. ទណ្ឌិតឈ្មោះ ផាន់ ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "គ" ចុះថ្ងៃទី ១៣.៥.៩៨ របស់តុលាការខេត្តកណ្តាល ។

៣១_ ទណ្ឌិតឈ្មោះ **ចេច ស្មើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ព" ចុះថ្ងៃទី ៤_៤_២០០០ របស់តុលាការខេត្តកណ្តាល ។

៣២_ ទណ្ឌិតឈ្មោះ **ហ៊ន នឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៦ឆ្នាំ តាមអំណាចសាលដីកាលេខ ៧៨ ចុះថ្ងៃទី ០២_០៤_៩៩ របស់សាលាឧទ្ធរណ៍ ។

៣៣_ ទណ្ឌិតឈ្មោះ **ស្រី ឆួន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៣_០៥_៩៧ របស់តុលាការខេត្តព្រះវិហារ ។

៣៤_ ទណ្ឌិតឈ្មោះ **ថ្លាង ហឿង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៧_០៥_៩៩ របស់តុលាការខេត្តព្រះវិហារ ។

៣៥_ ទណ្ឌិតឈ្មោះ **ចាន់ ទុជ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ១០_០៧_២០០០ របស់តុលាការខេត្តព្រៃវែង ។

៣៦_ ទណ្ឌិតឈ្មោះ **ម៉ុត ចាន់ធី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ១០_០៧_២០០០ របស់តុលាការខេត្តព្រៃវែង ។

៣៧_ ទណ្ឌិតឈ្មោះ **សុខ ម៉ុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ០២_០៣_២០០០ របស់តុលាការខេត្តព្រៃវែង ។

៣៨_ ទណ្ឌិតឈ្មោះ **ចាន់ ហេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ១៩_០៧_៩៩ របស់តុលាការខេត្តព្រៃវែង ។

៣៩_ ទណ្ឌិតឈ្មោះ **ជីង ណារ៉ាង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ១៩_០៧_៩៩ របស់តុលាការខេត្តព្រៃវែង ។

៤០_ ទណ្ឌិតឈ្មោះ **សុត សាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ០៩_០៨_៩៩ របស់តុលាការខេត្តព្រៃវែង ។

៤១_ ទណ្ឌិតឈ្មោះ **មុត ឆាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៤ ចុះថ្ងៃទី ០៨_១២_៩៩ របស់តុលាការខេត្តព្រៃវែង ។

៤២_ ទណ្ឌិតឈ្មោះ **ដោក ស្រ៊ុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១៨_០១_២០០០ របស់តុលាការខេត្តព្រៃវែង ។

៤៣_ ទណ្ឌិតឈ្មោះ **យ៉ាន ចាន់ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ "ក" ចុះថ្ងៃទី ១២_៤_៩៩ របស់តុលាការខេត្តកំពង់ចាម ។

៤៤_ ទណ្ឌិតឈ្មោះ **សេង ចាន់ថន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ៖

កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ "ក" ចុះថ្ងៃទី ១២-៤-៩៩ របស់តុលាការ ខេត្តកំពង់ចាម ។

៤៥-ទណ្ឌិតឈ្មោះ **ឡេ ប្រុស** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ១៣-០២-៩៧ របស់តុលាការខេត្តកំពត ។

៤៦-ទណ្ឌិតឈ្មោះ **ទេព ម៉ាន់នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ០៦-០១-៩៧ របស់តុលាការខេត្តកំពត ។

៤៧-ទណ្ឌិតឈ្មោះ **លី ម៉ុណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ២០- ៥-៩៧ របស់តុលាការខេត្តកំពត ។

៤៨-ទណ្ឌិតឈ្មោះ **ឃុត មិច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ១៨-៨-៩៨ របស់តុលាការខេត្តកំពត ។

៤៩-ទណ្ឌិតឈ្មោះ **ទូច តឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ២៩-០២-២០០០ របស់តុលាការខេត្តកំពត ។

**មាត្រា ៤ : ~** ត្រូវបានលើកលែងទោសអោយទណ្ឌិតចំនួន ៣នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១-ទណ្ឌិតឈ្មោះ **មូល ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០៣-៤-៩៦ របស់តុលាការខេត្តព្រះវិហារ ។

២-ទណ្ឌិតឈ្មោះ **ចែត អោត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២១-១០-៩៥ របស់តុលាការខេត្តព្រះវិហារ ។

៣-ទណ្ឌិតឈ្មោះ **ចេង សុផុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២២-១១-៩៤ របស់តុលាការខេត្តព្រះវិហារ ។

**មាត្រា ៥ : ~ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។**

**មាត្រា ៦ : ~ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេចជាស្ថាពរ ។**

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

១ ឯកឧត្តម **ច័ន្ទ តារី** ជាអគ្គលេខាធិការ នៃអាជ្ញាធរសវនកម្មជាតិ មានឋានៈស្មើនឹងរដ្ឋលេខាធិការ ។

២- ឯកឧត្តម **លុក ញ៉ិប** ជាអគ្គលេខាធិការរង នៃអាជ្ញាធរសវនកម្មជាតិ មានឋានៈស្មើនឹង អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរសវនកម្មជាតិ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ [illegible] ខែ [illegible] ឆ្នាំ ២០០១

[illegible] អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធិ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧២

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បញ្ឈប់ ឯកឧត្តម **កែវ ឡុងឌី** ពីតំណែងសមាជិកនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលតែងតាំងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត និង ឯកឧត្តម **កែវ ឡុងឌី** ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ១៨១ ច.ល

...ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

...រដ្ឋាភិបាល

...ណាឌី តាន់

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ង៉ែត ឫរី** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១*

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ : ១៧៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ សារី**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការអតីតយុទ្ធជនខេត្ត-ក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

# សំរេច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មការអតីតយុទ្ធជនខេត្ត-ក្រុង ចំនួន២៣ សំរាប់ដំណើរការអនុវត្តកម្មវិធីរំសាយទ័ព និងសមាហរណកម្ម នៅទូទាំងប្រទេសរួមមាន :

១- គណៈកម្មការអតីតយុទ្ធជន ខេត្តកណ្តាល
២- គណៈកម្មការអតីតយុទ្ធជន ខេត្តក្រចេះ
៣- គណៈកម្មការអតីតយុទ្ធជន ខេត្តកំពង់ចាម
៤- គណៈកម្មការអតីតយុទ្ធជន ខេត្តកំពង់ឆ្នាំង
៥- គណៈកម្មការអតីតយុទ្ធជន ខេត្តកំពង់ធំ
៦- គណៈកម្មការអតីតយុទ្ធជន ខេត្តកំពង់ស្ពឺ
៧- គណៈកម្មការអតីតយុទ្ធជន ខេត្តកំពត
៨- គណៈកម្មការអតីតយុទ្ធជន ខេត្តកោះកុង
៩- គណៈកម្មការអតីតយុទ្ធជន ខេត្តតាកែវ
១០-គណៈកម្មការអតីតយុទ្ធជនខេត្តបន្ទាយមានជ័យ
១១- គណៈកម្មការអតីតយុទ្ធជន ខេត្តបាត់ដំបង
១២- គណៈកម្មការអតីតយុទ្ធជន ខេត្តពោធិសាត់
១៣- គណៈកម្មការអតីតយុទ្ធជន ខេត្តព្រៃវែង
១៤- គណៈកម្មការអតីតយុទ្ធជន ខេត្តព្រះវិហារ
១៥- គណៈកម្មការអតីតយុទ្ធជន ខេត្តមណ្ឌលគិរី
១៦- គណៈកម្មការអតីតយុទ្ធជន ខេត្តរតនៈគិរី
១៧- គណៈកម្មការអតីតយុទ្ធជន ខេត្តសៀមរាប
១៨- គណៈកម្មការអតីតយុទ្ធជន ខេត្តស្ទឹងត្រែង
១៩- គណៈកម្មការអតីតយុទ្ធជន ខេត្តស្វាយរៀង
២០- គណៈកម្មការអតីតយុទ្ធជន ខេត្តឧត្តរមានជ័យ
២១- គណៈកម្មការអតីតយុទ្ធជន ក្រុងកែប
២២- គណៈកម្មការអតីតយុទ្ធជន ក្រុងប៉ៃលិន
២៣- គណៈកម្មការអតីតយុទ្ធជន ក្រុងព្រះសីហនុ

មាត្រា ២.-

គណៈកម្មការអតីតយុទ្ធជនខេត្ត -ក្រុងនីមួយៗ មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-អភិបាលខេត្ត -ក្រុង | ប្រធាន |
| ២-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៣-ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៤-ប្រធានមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ៥-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧-ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| ៨-ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩-ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១០-មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត -ក្រុង | សមាជិក |

១១- មេបញ្ជាការកងរាជអាវុធហត្ថខេត្ត- ក្រុង សមាជិក

១២- ស្នងការនគរបាលខេត្ត - ក្រុង សមាជិក

១៣- អភិបាលគ្រប់ស្រុក-ខ័ណ្ឌ សមាជិក

មាត្រា ៣.-

គណៈកម្មការអតីតយុទ្ធជនខេត្ត - ក្រុង មានសិទ្ធិបង្កើតលេខាធិការដ្ឋានប្រតិបត្តិមួយធ្វើជាសេនាធិការផ្ទាល់។

មាត្រា ៤.-

គណៈកម្មការអតីតយុទ្ធជនខេត្ត- ក្រុង មានភារកិច្ចអនុវត្តទៅតាមការតំរង់ទិស និងស្ថិតក្រោមការត្រួតពិនិត្យដោយផ្ទាល់ របស់ក្រុមប្រឹក្សាវំសាយកងកំលាំងប្រដាប់អាវុធ ក្នុងការបំពេញការងារ ដូចខាងក្រោម :

**ក-ភារៈការមុនពេលវំសាយ :**

សហការជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវំសាយកងកំលាំងប្រដាប់អាវុធ អនុវត្តការងារដូចខាងក្រោម :

-បណ្តុះបណ្តាលមន្ត្រីរបស់គណៈកម្មការអតីតយុទ្ធជនខេត្ត- ក្រុង និងលេខាធិការដ្ឋានប្រតិបត្តិ លើការងារត្រៀមរៀបចំ សំរាប់បំរើអោយការងារវំសាយទ័ព

-កំណត់ភារកិច្ចរបស់លេខាធិការដ្ឋានប្រតិបត្តិ ដើម្បីគ្រប់គ្រងយោធិនវំសាយក្នុងការរស់នៅតាមមូលដ្ឋាន

-កំណត់ចំនួនយោធិនវំសាយ ដែលត្រូវទៅរស់នៅតាមមូលដ្ឋាននីមួយៗតាមការស្ម័គ្រចិត្ត និងជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន ដើម្បីត្រៀមលក្ខណៈរៀបចំភូមិសាស្ត្រ សំរាប់ទទួលយោធិនវំសាយដែលទៅតាំងទីលំនៅ

-រៀបចំមណ្ឌលវំសាយ។

**ខ-ភារៈការក្នុងពេលវំសាយ :**

- ចូលរួមជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវំសាយកងកំលាំងប្រដាប់អាវុធ អនុវត្តការងារមួយចំនួនក្នុងមណ្ឌលវំសាយ :

+ទទួលយោធិនចូលក្នុងមណ្ឌលវំសាយ

+ស្រង់បញ្ជីឈ្មោះយោធិនក្នុងមណ្ឌលវំសាយដែលត្រូវទៅរស់នៅតាមមូលដ្ឋាន

+ជូនដំណើរយោធិនវំសាយ និងគ្រួសាររបស់គេទៅកាន់មូលដ្ឋាន ដែលគេទៅរស់នៅ

- រាយការណ៍ជាប្រចាំជូនអគ្គលខាធិការដ្ឋាន នៃក្រុមប្រឹក្សាវំសាយកងកំលាំងប្រដាប់អាវុធ អំពីសភាពការណ៍ទូទៅក្នុងពេលវំសាយ និងក្នុងការដឹកជញ្ជូនយោធិនវំសាយទៅកាន់មូលដ្ឋាន។

**គ-ភារៈការសមាហរណកម្ម :**

- ជូនដំណើរងដល់អាជ្ញាធរមូលដ្ឋានដើម្បីស្រង់បញ្ជីឈ្មោះយោធិនរំសាយដែលបានទៅរស់នៅជាក់ស្តែងតាមមូលដ្ឋាននីមួយៗ
- បំពេញបែបបទជូនយោធិនរំសាយ និងវាយតម្លៃអំពីតំរូវការជាក់ស្តែងរបស់គេនៅតាមមូលដ្ឋាន
- សហការជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ស្ថាប័នពាក់ព័ន្ធ សហគមន៍អ្នកផ្តល់ជំនួយ អង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាល បំពេញភារកិច្ចដូចខាងក្រោម :

 +ចុះបើកជំនួយឧបត្ថម្ភរបស់កម្មវិធីរំសាយទ័ព សំរាប់ដំណាក់កាលសមាហរណកម្មជូនយោធិនរំសាយតាមកម្មវិធីដែលបានគ្រោងទុក

 +ទ្រទ្រង់សុខភាពយោធិនរំសាយព្រមទាំងគ្រួសាររបស់គេដែលកំពុងរស់នៅតាមមូលដ្ឋាន និងផ្តល់ឧបករណ៍សំរួលរាងកាយជូនយោធិនរំសាយដែលពិការ

 +រៀបចំផែនការបណ្តុះបណ្តាលវិជ្ជាជីវៈ អោយបានសមស្របទៅតាមទីផ្សារការងារនៅតាមមូលដ្ឋានដែលយោធិនរំសាយកំពុងរស់នៅ

 +ដោះស្រាយរកការងារតាមលទ្ធភាពជាក់ស្តែង តាមមុខជំនាញដែលបានបណ្តុះបណ្តាល ទៅតាមលទ្ធភាព និងសមត្ថភាពរបស់យោធិនរំសាយម្នាក់ៗ

 +ពិនិត្យ និងដោះស្រាយតាមលទ្ធភាពជាក់ស្តែង នូវរាល់សំណូមពរចាំបាច់របស់យោធិនរំសាយក្នុងសហគមន៍

- រាយការណ៍លទ្ធផលនៃការផ្តល់ជំនួយរបស់កម្មវិធីសមាហរណកម្ម គុណភាពជំនួយ និងប្រសិទ្ធិភាពនៃការប្រើប្រាស់ជំនួយជូនអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- រាយការណ៍ជាប្រចាំជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ នូវសភាពការណ៍ប្រែប្រួលទូទៅរបស់យោធិនរំសាយ ដែលកំពុងរស់នៅតាមមូលដ្ឋាន
- បូកសរុបលទ្ធផលការងារប្រចាំខែ រាយការណ៍ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ ។

**មាត្រា៥.-**

សមាជិកគណៈកម្មការអតីតយុទ្ធជនខេត្ត-ក្រុង ត្រូវចូលរួមប្រជុំពិភាក្សាការងារ តាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

6

មាត្រា៧.-

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ -

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០០១ ហ៊ុន

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងនិង ស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- ដូចមាត្រា ៧
- កាលប្បវត្តិ-ឯកសារ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថានវ៉ាន់ដា

⁂

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើតវិទ្យាស្ថានឯកជនមួយ ដែលមានឈ្មោះថា " វិទ្យាស្ថានវ៉ាន់ដា " (Vanda Institute) ហៅកាត់ថា "វ.វ.ដ" ។ វិទ្យាស្ថាននេះ មានទីតាំងនៅអាគារលេខ ២១៦-២១៨ ផ្លូវម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២:** វិទ្យាស្ថានវ៉ាន់ដា ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រគណនេយ្យ ដែលមានរយៈពេលសិក្សា ៤ ឆ្នាំ ។ ក្នុងពេលអនាគត វិទ្យាស្ថានវ៉ាន់ដា អាចបើកវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬ ជំនាញឯកទេសផ្សេងៗ ឬ បង្កើតសាខារបស់វិទ្យាស្ថាន ស្របតាមការរីកចំរើន ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៣: មជ្ឈមណ្ឌលវ៉ាន់ដាគណនេយ្យ ត្រូវបានបញ្ចូលទៅក្នុងរចនាសម្ព័ន្ធវិទ្យាស្ថាន ។

មាត្រា ៤: លក្ខខណ្ឌទទួលសិស្សចូលរៀន :

- បេក្ខជនទាំងពីរភេទ ជាសិស្ស និស្សិត ប្រជាពលរដ្ឋ និង មន្ត្រីរាជការ ។
- បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

មាត្រា ៥: នាយកវិទ្យាស្ថានវ៉ាន់ដា មានភារកិច្ច :

- ជ្រើសរើស សិស្សអោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការស្រាវជ្រាវ ឯកសារសិក្សា ការប្រលងនិងប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆមាស ។

មាត្រា ៦: វិទ្យាស្ថាននេះ មានក្រុមប្រឹក្សាភិបាលមួយទទួលបន្ទុកគ្រប់គ្រងវិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានសមាជិកយ៉ាងតិច ០៣ រូប និងមានសញ្ញាប័ត្រម៉ាស្ទ័រយ៉ាងទាប ក្នុងមុខជំនាញនីមួយៗ សំរាប់ពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសិក្សា នៅដើមឆ្នាំសិក្សានីមួយៗ ។

មាត្រា ៧: ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើវិទ្យាស្ថាននេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៨: និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ "វិទ្យាសាស្ត្រគណនេយ្យ" ដែលផ្តល់អោយដោយ វិទ្យាស្ថានវ៉ាន់ដា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញនិងអនុវត្តតាមនិយាមអប្បបរមា នៃការទទួលស្គាល់គុណភាពអប់រំថ្នាក់ឧត្តមសិក្សា ។

មាត្រា ៩: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលរាជធានីភ្នំពេញ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងវិទ្យាស្ថានវ៉ាន់ដា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- តាមសំណើរបស់ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

**សំរេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំក្រុមនានា របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានទីតាំង នៅទីស្តីការក្រសួងផែនការ ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន ជាអង្គភាពប្រតិបត្តិ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដឹកនាំនិងគ្រប់ គ្រងដោយ អគ្គលេខាធិការ មួយរូប និងមាន អគ្គលេខាធិការរង ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានបេសកកម្ម ដាក់អោយដំណើរការ នូវកម្មវិធី និងគំរោងអភិវឌ្ឍន៍សង្គមកិច្ច តាមការណែនាំនិងការចង្អុលទិស របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ សង្គមកិច្ច ។

ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ :

- សិក្សានិងលើកសំណើដាក់ជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច នូវកម្មវិធី និងគំរោងអភិវឌ្ឍន៍ សង្គមកិច្ច រយៈពេលខ្លី មធ្យម និងវែង
- ជំរុញ និងធ្វើការតាមដាន វាយតំលៃ ការអនុវត្តន៍ កម្មវិធី និងគំរោងអភិវឌ្ឍន៍សង្គមកិច្ចទាំងនោះ
- ធ្វើរបាយការណ៍យ៉ាងទៀងទាត់ អំពីលទ្ធផលនៃការអនុវត្តន៍ ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដើម្បីដាក់ជូន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ធ្វើទស្សនាទាន ផែនការកម្ម ការដាក់អោយដំណើរការ ការសំរបសំរួល ការតាមដាន និងការ វាយតំលៃលើកម្មវិធី និងគំរោងកាត់បន្ថយភាពក្រីក្រ ប្រព័ន្ធពត៌មានភាពក្រីក្រ និងអង្កេត ស្ថានភាពភាពក្រីក្រនៅកម្ពុជា
- តាមដានដំណើរការបែងចែកជំនួយ សំរាប់ការងារសង្គមកិច្ច
- បំពេញមុខងារ និងភារកិច្ចចាំបាច់ដទៃទៀត ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចប្រគល់ជូន ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវធ្វើការប្រជុំការងារប្រចាំរៀងរាល់ខែ តាមការ អញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសិទ្ធិ ប្រើប្រាស់ត្រា របស់ក្រសួងផែនការ ដើម្បីបំពេញការងាររបស់ខ្លួន ។

**មាត្រា ៥.-**

អគ្គលេខាធិការ មានសិទ្ធិលើកសំណើជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដើម្បីពិនិត្យសំរេច លើការតែងតាំង ឬការដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានរចនាសម្ព័ន្ធ ដូចតទៅ:

១- ក្រុម រដ្ឋបាលទូទៅ និងផ្គត់ផ្គង់

២- ក្រុម តាមដាន និងវិភាគភាពក្រីក្រ

៣- ក្រុម ការងារតាមផ្នែក

៤- ក្រុម ជំនួយសង្គមកិច្ច

ក្រុមនីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមាន អនុប្រធាន ជាជំនួយការតាមការចាំបាច់ ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។

**មាត្រា ៧.-**

ការបែងចែកលំអិត នូវភារកិច្ចរបស់បុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការក្នុង អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្ដីសំរេច របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ៨.-**

**ក្រុមរដ្ឋបាលទូទៅនិងផ្គត់ផ្គង់** មានមុខងារ និងភារកិច្ច ដូចតទៅ:

- សំរបសំរួលនូវរាល់សកម្មភាព ផ្នែករដ្ឋបាល
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាល
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល
- បូកសរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- ផ្ដល់ការគាំទ្រផ្នែកភស្តុភារចាំបាច់ ដល់អគ្គលេខាធិការដ្ឋាន
- លើកសំណើ និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំ
- ប្រមូលផ្ដុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- តាមដាន និងរំលឹកការអនុវត្តន៍ថវិកា និងការគ្រប់គ្រងគណនេយ្យ
- ប្រមូលផ្ដុំតំរូវការ រួចធ្វើកម្មវិធីចំណាយឱ្យបានសមស្រប
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភិធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើរបាយការណ៍ចំណាយប្រចាំត្រីមាស
- សំរបសំរួល និងតាមដានហិរញ្ញប្បទាន នៃការអភិវឌ្ឍន៍សង្គមកិច្ច តាមក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បី រ៉ាប់រងសហថាមពលនៃធនធាន និងធ្វើអោយសំរេចប្រព័ន្ធសេដ្ឋកិច្ចមាត្រដ្ឋាន
- រ៉ាប់រងសេវាប័ណ្ណសារ ឯកសារ និងការបកប្រែភាសា ។
- រៀបចំ និងសំរួលកិច្ចប្រជុំ និងការពិភាក្សារបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

- បូកសរុប និងធ្វើរបាយការណ៍ការងារ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

**មាត្រា ៩.-**

**ក្រុមតាមដាន និងវិភាគភាពក្រីក្រ** មានមុខងារ និងភារកិច្ច ដូចតទៅ:

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ជាមួយក្រសួងស្ថាប័ន និងអង្គការជាតិ អង្គការអន្តរជាតិដែលពាក់ព័ន្ធ
- រៀបចំផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង សំរាប់កាត់បន្ថយភាពក្រីក្រនៅកម្ពុជា
- រៀបចំធ្វើអង្កេតស្ថានភាពក្រីក្រនៅកម្ពុជាជាបន្តបន្ទាប់តាមការចាំបាច់
- រៀបចំប្រព័ន្ធផ្សព្វផ្សាយពីស្ថានភាព និងការរីកចំរើននៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងារកាត់បន្ថយភាពក្រីក្រ និងស្ថានភាពក្រីក្រនៃកម្ពុជា បច្ចុប្បន្ន ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ១០.-**

**ក្រុមការងារតាមផ្នែក** មានមុខងារ និងភារកិច្ច ដូចតទៅ :

- ផ្តល់យោបល់ និងធ្វើជាជំនួយការបច្ចេកទេស ដល់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ជំរុញ និងសំរបសំរួល ការអនុវត្តន៍ផែនការសកម្មភាព កម្មវិធី និងគំរោងនានា តាមផ្នែកពាក់ព័ន្ធ រួមមានផ្នែក កសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល អប់រំ កិច្ចការនារី និងសង្គមកិច្ចការងារ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គមកិច្ច
- រៀបចំរងអន្តរប្រព័ន្ធបច្ចេកទេស និងទំនាក់ទំនង រវាងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និងក្រសួងស្ថាប័នពាក់ព័ន្ធ
- តាមដាន និងវាយតំលៃការអនុវត្តន៍ផែនការសកម្មភាព កម្មវិធី និងគំរោងទាំងអស់នោះ
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពអនុវត្តន៍ការងារតាមផ្នែក និងលទ្ធផល ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ១១.-**

**ក្រុមជំនួយសង្គមកិច្ច** មានមុខងារ និងភារកិច្ច ដូចតទៅ :

- តាមដានរាល់ការបែងចែកជំនួយ របស់ប្រទេស និងស្ថាប័នអន្តរជាតិ ម្ចាស់អំណោយនានា សំរាប់ការងារសង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ក្នុងគោលបំណងធានាអោយបាន នូវការបែងចែកអោយដល់គោលដៅ និងការប្រើប្រាស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើននូវជំនឿជឿជាក់ ពីប្រទេសផ្តល់ជំនួយ
- វិភាគអំពីសមាមាត្រ នៃការបែងចែកអោយបានសមស្រប តាមទំហំការងារភារកិច្ច
- ប្រៀបធៀបសមាមាត្រ នៃការចំណាយរវាងផ្នែកសេដ្ឋកិច្ច យោធា នគរបាល និងការចំណាយផ្នែកសង្គមកិច្ច លើផ្នែកផ្សេងៗទៀតនៃថវិកាជាតិ សំដៅអោយមានការចំណាយយ៉ាងសមស្រប ទៅលើផ្នែកសង្គមកិច្ច

- តាមដានការអភិវឌ្ឍន៍ នៃការចំណាយផ្នែកសង្គមកិច្ច
- យកចិត្តទុកដាក់ ធ្វើទំនាក់ទំនងជាមួយ អង្គការអន្តរជាតិនានា ដើម្បីអោយចូលរួមជួយគាំទ្រ និងទ្រទ្រង់ការអភិវឌ្ឍន៍សង្គមកិច្ចនៅកម្ពុជា ទាំងផ្នែកបច្ចេកទេស ថវិកា និងសំភារៈ
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពអនុវត្តន៍ជំនួយសង្គមកិច្ច និងលទ្ធផលជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ១២.-**

ក្រសួងស្ថាប័នពាក់ព័ន្ធនីមួយៗ មានភារកិច្ចតែងតាំង ក្រុមការងារអភិវឌ្ឍន៍សង្គមកិច្ច របស់ខ្លួន ដើម្បីទទួលបន្ទុក :

- រាប់រងការធ្វើទំនាក់ទំនង ជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- ធានាប្រសិទ្ធភាពនៃការដាក់ឱ្យដំណើរការ នូវគំរោងអភិវឌ្ឍន៍សង្គមកិច្ច ក្នុងក្រសួងស្ថាប័នរបស់ខ្លួន
- ចូលរួមរៀបចំគំរោងអភិវឌ្ឍន៍សង្គមកិច្ច សំរាប់ក្រសួងស្ថាប័នរបស់ខ្លួន
- ធ្វើជាអន្តរប្រព័ន្ធ រវាងគំរោងអភិវឌ្ឍន៍សង្គមកិច្ច និងគំរោងដទៃទៀត របស់ក្រសួងស្ថាប័ន របស់ខ្លួន ។

ក្រុមការងារអភិវឌ្ឍន៍សង្គមកិច្ច នៃក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់នេះ ជាដៃគូពិភាក្សាជាមួយក្រុមការងារតាមផ្នែក របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច លើរាល់ការងារសំរាប់កិច្ចអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ១៣.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬ អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ។ ល័ក្ខខ័ណ្ឌនៃលាភការរបស់បុគ្គលិកជាប់កិច្ចសន្យា និង ប្រាក់បំណាច់ពិសេស សំរាប់បើកជូនបុគ្គលិកនៃមុខងារសាធារណៈ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៤.-**

សមាជិក និងបុគ្គលិកទាំងអស់ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្តល់មកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងផែនការ តាមសំណូមពររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសមាជិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានភារកិច្ចរៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

**ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច**

**ឆាយ ថន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័នរដ្ឋ
- ឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និង ការគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៨០ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី លិខិតអនុញ្ញាតសាងសង់
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០១

**សំ : រ : ច**

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

រៀបចំរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ដែលមានទំហំ ៥០៨ ហិកតាស្ថិតនៅក្នុងឃុំផ្សារដែក និងឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល។

**មាត្រា ២ .-**

គោលបំណងដើម្បី :

- អភិរក្សកេរដំណែលបេតិកភ័ណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ
- អភិវឌ្ឍតំបន់ទេសចរណ៍
- អភិរក្សបរិស្ថាន វប្បធម៌ ធម្មជាតិ។

**មាត្រា ៣ .-**

រមណីយដ្ឋាននេះ ត្រូវបានប្រកាសជាតំបន់បំរើផលប្រយោជន៍សាធារណៈ។

# ជំពូកទី ២
# ការកំណត់ និង ការគ្រប់គ្រងតំបន់

**មាត្រា ៤ .-**

រមណីយដ្ឋាននេះ ចែកចេញជា ៣ តំបន់ផ្សេងៗ គ្នា :

-<u>តំបន់ទី១</u> : តំបន់អភិរក្សបេតិកភ័ណ្ឌប្រវត្តិសាស្ត្រហៅថា **តំបន់ស្នូល** ដែលស្ថិតក្នុងរង្វង់អ័ក្សផ្លូវជុំវិញជើងភ្នំ ដែលមានទំហំ ៧៥ ហិកតា ។

-<u>តំបន់ទី២</u> : តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចទេសចរណ៍ហៅថា **តំបន់ទ្រនាប់** ដែលស្ថិតក្នុងចន្លោះព្រំប្រទល់អ័ក្សផ្លូវជុំវិញជើងភ្នំ និងខ្សែបន្ទាត់ព្រំប្រទល់ a, b, c, d, e, f, g, h, i, j, k, l, m ដែលមានទំហំ ២១៧ ហិកតា។

-**តំបន់ទី៣** : តំបន់អភិរក្ស និងថែរក្សាការពារបរិស្ថានធម្មជាតិហៅថា **តំបន់វណប** ដែលស្ថិតនៅ ចន្លោះខ្សែបន្ទាត់ព្រំប្រទល់ a, b, c, d, e, f, g, h, i, j, k, l, m និង ខ្សែបន្ទាត់ព្រំប្រទល់ A, B, C, D, E, F, G, H, I, J, K, L ដែលមានទំហំ ២១២ ហិកតា។

និយាមការនៃចំណុចព្រំប្រទល់ a, b, c, d, e, f, g, h, i, j, k, l, m និង A, B, C, D, E, F, G, H, I, J, K, L មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១

- ខ្សែបន្ទាត់ព្រំប្រទល់មានក្នុងឧបសម្ព័ន្ធទី ២
- ប្លង់កំណត់តំបន់អភិវឌ្ឍន៍ភ្នំព្រះរាជទ្រព្យក្នុងដំណាក់កាលដំបូងមានក្នុងឧបសម្ព័ន្ធទី ៣។

**មាត្រា ៥ .-**

**តំបន់ស្នូល :**

- តំបន់នេះត្រូវអភិរក្ស និង ការពារ រាល់សកម្មភាពនានារួមមាន ការជីក កកាយ រុះរើ និង កសាងសំណង់ថ្មីត្រូវហាមឃាត់

-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានភារកិច្ចទទួលបន្ទុកការពារ អភិរក្ស និង ទ្រទ្រង់តំបន់ស្នូលនៃរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ

-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាស្ថាប័នមានសមត្ថកិច្ចតែមួយគត់ ដែលអាចចេញលិខិតអនុញ្ញាត អោយធ្វើការជីកកកាយ រុះរើ ជួសជុល ពង្រឹងភាពរឹងមាំរបស់សំណង់ចាស់ដែលមានស្រាប់ ឬ កសាងសំណង់ថ្មីក្នុងរង្វង់តំបន់ស្នូល បន្ទាប់ពីបានពិគ្រោះយោបល់ពីក្រសួងពាក់ព័ន្ធ និង អាជ្ញាធរដែនដី

-រាល់ការអនុញ្ញាតណាដែលចេញដោយស្ថាប័នដទៃផ្សេងពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវចាត់ទុក ជាមោឃៈ ។

**មាត្រា ៦ .-**

**តំបន់ទ្រនាប់ :**

តំបន់នេះសុទ្ធសឹងជាសំណង់លំនៅឋាន ដែលមានស្រាប់នឹងសំណង់ធ្វើអាជីវកម្មបំរើអោយផ្នែកសេវាកម្មទេសចរណ៍ជាសំខាន់ ។

**១._ទិដ្ឋភាពសំណង់ :**

-រាល់សំណង់ក្នុងតំបន់ទ្រនាប់តម្រូវអោយមានច្បាប់អនុញ្ញាតសាងសង់ ដោយត្រូវរក្សានូវរចនាបថខ្មែរតាមបែបស្ថាបត្យកម្ម និង ទំនៀមទំលាប់វប្បធម៌ជាតិក្នុងតំបន់ដែលមានស្រាប់

- ច្បាប់អនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមាន ទីតាំង និម្មាបនកម្ម ទំហំ ឬ ទិដ្ឋភាពខាងក្រៅ ដែលអាចនាំអោយប៉ះពាល់ទិដ្ឋភាពរួមនៃរមណីយដ្ឋាន

- លិខិតអនុញ្ញាតអោយសាងសង់នឹងអាចអនុញ្ញាតឱ្យបានតែក្នុងករណីស្ថិតក្រោមបញ្ញត្តិពិសេស ។

២. **ការបោះទីតាំងធៀបនឹងផ្លូវសាធារណៈ :**

២.១. **ផ្លូវតំរង់ទីតាំងសំណង់ជុំវិញ** : ត្រូវរក្សាទុកប្រវែង ១០,០០ម ចាប់ពីអ័ក្សផ្លូវ ។

២.២. **គម្លាត :**

- សំរាប់លំនៅឋានត្រូវបោះទីតាំងឃ្លាតឋយពីផ្លូវតំរង់យ៉ាងតិច ៤,០០ម
- សំរាប់អគារលក់ដូរ បណ្ដាសំណង់ត្រូវបោះទីតាំងលើបន្ទាត់ផ្លូវតំរង់ផ្លូវ

២.៣. **កំពស់ :**

- សំរាប់លំនៅឋានមិនអោយលើសពី ៦,៥០ម ពីដីមកទល់នឹងស្លាបជញ្ជាំង
- សំរាប់អគារលក់ដូរមិនអោយលើសពី ៤,៥០ម ពីដីមកទល់នឹងស្លាបជញ្ជាំង ។

៣. **ផ្ទៃបាត :**

ជាទូទៅក្នុងតំបន់រមណីយដ្ឋាន ផ្ទៃបាតសំណង់ធៀបនឹងផ្ទៃក្រឡារបស់ដីឡូត៍ ត្រូវកំណត់ដូចខាងក្រោម :

- សំរាប់លំនៅឋានមិនអាចលើសពី ៣៥% ឡើយ លើកលែងតែក្នុងករណីពិសេស ដូចអគារលក់ដូរជាដើម ។ ចំពោះផ្ទៃក្រឡាដែលនៅសល់ពីសំណង់ត្រូវរៀបចំជាសួន ដោយទុកឱ្យមានដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ

- សន្ទភាពគំរិតអតិបរមាស្របច្បាប់របស់សន្ទស្សន៍នៃការប្រើប្រាស់មិនលើសពី ០,៤០ លើកលែងតែក្នុងករណីពិសេស ។

៤. **ការផ្គត់ផ្គង់ទឹកស្អាត និង ការបញ្ចេញចោលទឹកកខ្វក់ :**

- បណ្ដាសំណង់ទាំងអស់ត្រូវធានាអោយមានការផ្គត់ផ្គង់ទឹកស្អាត ដែលតម្រូវអោយមានក្នុងច្បាប់អនុញ្ញាតសាងសង់ ។ ក្នុងករណីដែលបណ្ដាញទឹកស្អាតពុំផ្គត់ផ្គង់អោយទៅដល់ទីដី អ្នកស្នើសុំច្បាប់អនុញ្ញាតសាងសង់ ត្រូវបង្ហាញភស្តុតាងថាខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតបានក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន ដូចជាការជីកអណ្ដូងថ្មីក្ដី

- ម្ចាស់សំណង់ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យតាមបទដ្ឋាន ដែលក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់បានផ្សព្វផ្សាយអោយប្រើប្រាស់ហើយ

- ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយម្ចាស់សំណង់មានភារៈចាំបាច់ត្រូវគ្រោងសំអាត និង បញ្ចេញទឹក ដែលប្រើប្រាស់ហើយទៅទីធម្មជាតិតាមរយៈបង្គន់អនាម័យ

- សំណុំលិខិតសុំច្បាប់អនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

៥. តំបន់ពិកនិក

- ហាមមិនអោយមានសំណង់ជារោង គ្រែ ឬ បង្គា សំរាប់បំរើអោយការលក់ដូរក្នុងតំបន់ លក់ដូរម្ហូបអាហារគ្រប់ប្រភេទ ឬ រៀបចំជាឯកជននូវសំភារៈបរិក្ខារសំរាប់ការសំរាកលំហែកាយរបស់ទេសចរ

- ត្រូវថែរក្សាអនាម័យអោយស្អាតជាប់ជានិច្ច ដោយត្រូវចាត់តាំងឱ្យមានបង្គន់អនាម័យ និង បណ្តាញទឹកស្អាត និង ដោះស្រាយលូបង្ហូរទឹកប្រើប្រាស់ប្រកបដោយលក្ខណៈការពារបរិស្ថាន

- ត្រូវដាំដើមឈើដែលផ្តល់ម្លប់សំរាប់ទេសចរជ្រកសំរាក ព្រមទាំងមានចំណតរថយន្តទេសចរណ៍ ធុនតូចគ្រប់ប្រភេទបំរើអោយតំបន់នេះ ។ ការដាំដើមឈើក្នុងតំបន់នេះជាភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៦. សមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង

សមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ក្នុងរង្វង់បរិវេណតំបន់ទ្រនាប់រួមមាន :

៦.១. សំណង់ពុំបាច់អោយមានច្បាប់សាងសង់ :

- សាលាឆទាន
- លំនៅឋានស្រាលៗ ពុំមានរៀបឥដ្ឋ ឬ បេតុង
- តូបតូចៗ សំរាប់លក់ដូរ ព្រឹត្តិប័ត្រពត៌មាន សារពត៌មាន ...

ចំពោះសំណង់ខាងលើនេះ ត្រូវមានការយល់ព្រមជាមុនពីមេឃុំ អភិបាលស្រុក

- ការងារថែទាំ និង ជួសជុលដែលពុំមានកែប្រែដល់រចនាសម្ព័ន្ធ ឬ ទិដ្ឋភាពនៃសំណង់

៦.២. សំណង់អគារលក់ដូរ ឬ សំណង់ផ្សេងៗទៀត ត្រូវមានលិខិតអនុញ្ញាតសាងសង់ ពីអភិបាលខេត្ត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបន្ទាប់ពីបានការឯកភាពពីផ្នែកវិស័យទេសចរណ៍ និង វប្បធម៌ រួចមក ។

មាត្រា ៧ ._

តំបន់រណប :

តំបន់នេះបំរើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយផ្សារភ្ជាប់ ជាមួយការរក្សានូវប្រពៃណីធ្វើអាជីវកម្ម កសិកម្ម បរិស្ថាន ធម្មជាតិ ជុំវិញតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច ទេសចរណ៍ និង តំបន់អភិរក្សបេតិកភ័ណ្ឌប្រវត្តិសាស្ត្រ ។

# ជំពូកទី ៣
# ការគ្រប់គ្រង និង ការអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍

**មាត្រា ៨ .-**

ការរៀបចំអភិវឌ្ឍន៍ខាងផ្នែកសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋាន ត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់ក្រសួងទេសចរណ៍ តាមគំរោងប្លង់មេមួយដែលត្រូវបានទទួលអនុម័តពីរាជរដ្ឋាភិបាល ។

**មាត្រា ៩ .-**

រាល់ការងារធ្វើអាជីវកម្មខាងផ្នែកសេវាទេសចរណ៍ មិនត្រូវធ្វើអោយប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី វប្បធម៌ជាតិ សង្គម និង បរិស្ថាន និងត្រូវធានាអោយមានអនាម័យនិងសុខុមាលភាពដល់ភ្ញៀវទេសចរណ៍ ដែលមកកំសាន្តនៅទីនោះ ។

# ជំពូកទី ៤
# សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និង របៀបរៀបរយ

**មាត្រា ១០ .-**

អាជ្ញាធរដែនដីទទួលខុសត្រូវ ធានានូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និង របៀបរៀបរយក្នុងរមណីយដ្ឋាន ជូនដល់ទេសចរដែលមកលេងកំសាន្ត ។

# ជំពូកទី ៥
# ការគ្រប់គ្រងថវិកា

**មាត្រា ១១ .-**

ចំណូល និង ចំណាយជាកម្មវត្ថុនៃថវិកាឧបសម្ព័ន្ធក្នុងក្របខ័ណ្ឌច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ន.ស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយដែលត្រូវបានកែប្រែតាមព្រះរាជក្រមលេខ ១១/ន.ស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ដោយព្រះរាជក្រមលេខ នស.រកម ១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩។

ប្រាក់ចំណូលដែលបានមកពីប្រភពខាងលើនេះមាន :

- ការចូលទស្សនាកំសាន
- កំរៃយកពីអាជីវកម្មថតរូប ឬ ថតខ្សែភាពយន្តលក់ដូរគ្រប់ប្រភេទក្នុងតំបន់រមណីយដ្ឋាននេះ
- ពិធីសិល្បៈ ពិធីវប្បធម៌ និង ពិធីផ្សេងៗទៀត ដែលចាត់ចែងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ ឬ ដោយឯកជនដែលបានទទួលការអនុញ្ញាតពីអាជ្ញាធរដែនដី
- ការជួល ឬ ការអនុញ្ញាតអោយប្រើប្រាស់ដីធ្លីដែលគ្រប់គ្រងដោយអាជ្ញាធរដែនដី

# ជំពូកទី ៦
# អវសានប្បញ្ញត្តិ

**មាត្រា ១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០១

ហ៊ុន សែន

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**អ៊ឹម ឈុនលឹម**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

### តារាងសម្រង់និយាមការនៃចំនុចព្រំប្រទល់ផ្នែកខាងក្រៅ របស់តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចទេសចរណ៍ (តំបន់២)

| ល.រ | X(E) | Y(N) |
|---|---|---|
| a | 474705.03 | 1304886.90 |
| b | 475180.99 | 1304309.39 |
| c | 475567.11 | 1304330.35 |
| d | 476211.78 | 1303127.94 |
| e | 476194.07 | 1302994.03 |
| f | 475968.68 | 1302920.21 |
| g | 476128.19 | 1302448.37 |
| h | 475556.83 | 1302381.38 |
| i | 475009.66 | 1302539.27 |
| j | 474742.69 | 1303305.68 |
| k | 474033.76 | 1304046.80 |
| l | 474033.69 | 1304255.43 |
| m | 474602.00 | 1304881.45 |

### តារាងសម្រង់និយាមការនៃចំនុចព្រំប្រទល់ផ្នែកខាងក្រៅ របស់តំបន់អភិរក្ស និង ថែរក្សាបរិស្ថានធម្មជាតិ (តំបន់៣)

| ល.រ | X(E) | Y(N) |
|---|---|---|
| A | 474435.05 | 1305460.34 |
| B | 474850.04 | 1305458.15 |
| C | 474847.31 | 1304940.15 |
| D | 475640.60 | 1304613.97 |
| E | 476393.97 | 1303542.98 |
| F | 476397.89 | 1302768.95 |
| G | 476183.87 | 1302766.08 |
| H | 476174.48 | 1302314.12 |
| I | 474929.42 | 1302304.69 |
| J | 473942.00 | 1303744.91 |
| K | 473948.32 | 1304944.89 |
| L | 474432.32 | 1304942.34 |

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលសមាសភាព នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យ លេខ៤៣ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

# សម្រេច

**មាត្រា ១.-**

ត្រូវបានកែសំរួលមាត្រា២ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដែលមានសមាសភាពថ្មីដូចខាងក្រោម :

- ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន
- ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស សុភា** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- ឯកឧត្តម **ចាន់ តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **លី ធុច** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា សមាជិក
- លោកជំទាវ **យូ អយ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក
- ឯកឧត្តម **នូ សាំងខន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក
- ឯកឧត្តម **ឆាន់ សាផាន់** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
- ឯកឧត្តម ឧត្តមសេនីយ៍ឯក **មល់ រឿប** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារយោធា សមាជិក
- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ភួង ស៊ីផាន** នាយរងសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានី ភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងនិង ស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
 ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ « **ធិបឌិន្ទ** » ប្រគេនព្រះសាសនសំវរ អ៊ំ **លីមហេង** រាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ ដែលមានព្រះគុណបំណាច់ និងស្នាព្រះហស្ថដ៏ខ្ពង់ខ្ពស់ បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការស្តារឡើនសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច និងព្រះពុទ្ធសាសនា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១*

<u>ចម្លងជូន</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*

នាយករដ្ឋមន្ត្រី

សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៦៨...អនក្រ·បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**ប្រការ១** : ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៤ រូប ដែលបានបរិច្ចាគជីហ្វូសស្វាត ចំនួន ៧០០ តោន សំរាប់ចែកជូនប្រជាពលរដ្ឋធ្វើស្រែប្រាំង និងវស្សា ដូចមានរាយនាមជូនខាងក្រោម ÷

១- លោក **គីម សុមិន្ត** ថវិកា ចំនួន ១៣.៤៥០ ដុល្លា

២- លោក **អ៊ូ សារី** ថវិកា ចំនួន ១៣.៤៥០ ដុល្លា

៣- លោក **គង់ ម៉ុក** ថវិកា ចំនួន ១៣.៤៥០ ដុល្លា

៤- លោក **ស សុខា** ថវិកា ចំនួន ១៣.៤៥០ ដុល្លា

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តន៍អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.....៧. ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

H.ISP,Decision

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦៩ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំង លោក **ឈៃ ម៉េងអ៊ាង** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ ជាប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូនៈ**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ÷

១- លោក រស់ វុណ្ណ ជានាយករង ខុទ្ទកាល័យក្រសួងមហាផ្ទៃ

២- លោក សូ សុខខេង ជាអគ្គនាយករងទី ១ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៧ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនមន្ត្រី ចំនួន ១១ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនអង្គភាព ចំការកៅស៊ូជុប ថ្មពេជ្រ និង ច្រាប នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ដូចមានរាយនាមខាងក្រោមនេះ÷

| | | | |
|---|---|---|---|
| ១-លោក | **សោម** | **សារិន** | ប្រធានមូលដ្ឋាន ជុប |
| ២ លោក | **វ៉ាន់** | **សារេត** | ប្រធានមណ្ឌល មូលដ្ឋាន ជុប |
| ៣-លោក | **ឃិន** | **ច័ន្ទសុធី** | ប្រធានមណ្ឌល មូលដ្ឋាន ជុប |
| ៤-លោក | **ស៊ឹម** | **លាងស្រេង** | ប្រធានមណ្ឌល មូលដ្ឋាន ជុប |
| ៥-លោក | **មាស** | **មានិត** | ប្រធានមណ្ឌល មូលដ្ឋាន ថ្មពេជ្រ |
| ៦-លោក | **ហៃ** | **អេងលាប** | ប្រធានមណ្ឌល មូលដ្ឋាន ថ្មពេជ្រ |
| ៧-លោក | **ជៀម** | **ច័ន្ទខេមរិន្ទ្រ** | ប្រធានមណ្ឌល មូលដ្ឋាន ថ្មពេជ្រ |
| ៨-លោក | **អ៊ុង** | **រិទ្ធី** | ប្រធានមណ្ឌល មូលដ្ឋាន ច្រាប |
| ៩-លោក | **ពៅ** | **សារុន** | ប្រធានមណ្ឌល មូលដ្ឋាន ច្រាប |

១០-លោក **លន់ សារ៉ុត** ប្រធានអយ្យការ អមសាលាដំបូង ...

១១-លោក **ហេង ឡឿន** ប្រធានមន្ទីរពិសោធន៍

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ ✓

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការប្រគល់សិទ្ធិចុះហត្ថលេខានៅក្នុង

## គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ / នស / ៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ / អនក្រ.បក / ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ / អនក្រ.បក / ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល និងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**ប្រការ ១** : ប្រគល់សិទ្ធិចុះហត្ថលេខានៅក្នុងគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានដូចតទៅ ÷

**ក-** ឯកឧត្តម **គាត ឈន់** អនុប្រធានទី ១ : មានសិទ្ធិចុះហត្ថលេខាលើលិខិតទាំងឡាយ ដែលមានកំរិតនយោបាយ និងលិខិត ឬ ឯកសារ ដូចមានខាងក្រោម :

- លិខិតសុំយោបល់សំរេចពីប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ពីរាជរដ្ឋាភិបាល

- លិខិតទំនាក់ទំនងជាមួយប្រធាន ឬ តំណាងជាន់ខ្ពស់នៃស្ថាប័នផ្តល់ជំនួយ
- ប្រកាសតែងតាំងតួនាទីរបស់មន្ត្រីរាជការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពីថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម
- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋ និងអភិបាលខេត្ត-ក្រុងដែលពាក់ព័ន្ធការងារគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។

ខ- ឯកឧត្តម **ចម ប្រសិទ្ធ** អនុប្រធាន : មានសិទ្ធិចុះហត្ថលេខាលើលិខិត ឬឯកសារដូចខាងក្រោម :

- លិខិតសុំយោបល់សំរេចពីប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ពីរាជរដ្ឋាភិបាល ក្នុងការលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន
- លិខិតជូនប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សុំពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជន
- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋ និងអភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធការងារគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន
- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋឬតំណាងជាន់ខ្ពស់នៃអង្គការអាស៊ាន ក្នុងក្របខ័ណ្ឌអាស៊ាន ។

គ- ឯកឧត្តម **គង់ ទិមុល** អនុប្រធាន : មានសិទ្ធិចុះហត្ថលេខាលើលិខិត ឬឯកសារដូចខាងក្រោម :

- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋ និងអភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធការងារប្រចាំរបស់គណៈកម្មាធិការវិនិយោគកម្ពុជា
- លិខិតអញ្ជើញប្រធានស្ថាប័នរាជរដ្ឋាភិបាល និងអភិបាលខេត្ត-ក្រុង សំរាប់ចូលរួមប្រជុំច្រកចេញចូលតែមួយ
- លិខិតអនុញ្ញាតអោយនាំចូលនូវគ្រឿងចក្រ សំភារៈ ឧបករណ៍ បរិក្ខារ វត្ថុធាតុដើម ក្នុងក្របខ័ណ្ឌវិនិយោគឯកជន និងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្ញើត្រង់ទៅទីចាត់ការគយនិងរដ្ឋាករអនុវត្តបន្ទាប់ពីការប្រជុំអន្តរស្ថាប័ន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតពន្យាសុពលភាពនៃការអនុញ្ញាតិនាំចូល ។

**ប្រការ ២** : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិចុះហត្ថលេខាលើលិខិត និងឯកសារដូចមានខាងក្រោម ÷

- លិខិតដកប្រាក់តក់ពីធនាគារជាតិរបស់បណ្តាក្រុមហ៊ុនវិនិយោគ
- អាជ្ញាប័ណ្ណវិនិយោគ
- លិខិតដែលទាក់ទងនឹងកិច្ចការសីរបស់រលៃផ្ទៃក្នុងនិងកិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លិខិតចាត់តាំងមន្ត្រីចូលរួមសិក្ខាសាលា ឬប្រជុំផ្សេងៗ
- លិខិតដែលទាក់ទងនឹងកិច្ចការពាក់ព័ន្ធការគ្រប់គ្រងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លិខិតដែលទាក់ទងនឹងការគ្រប់គ្រងវិមានរដ្ឋាភិបាល និងបរិវេណនៃវិមាន

- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេស នៅក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងបណ្ដាក្រសួង- ស្ថាប័នផ្សេងៗ នៃរាជរដ្ឋាភិបាលតំណាងរបស់អ្នកផ្ដល់ជំនួយ និងវិនិយោគនានា ។

**ប្រការ ៣** : អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ មានសិទ្ធិចុះហត្ថលេខាលើលិខិតដូចមានខាងក្រោម ÷

- លិខិតដែលទាក់ទងនឹងកិច្ចការសំរបសំរួលផ្ទៃក្នុង និងកិច្ចការរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេស នៅក្នុងទំនាក់ទំនងរវាង គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងសមភាគីនានានៅតាមបណ្ដាក្រសួង- ស្ថាប័នផ្សេងៗ នៃរាជរដ្ឋាភិបាល
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនង គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងតំណាងអ្នកផ្ដល់ជំនួយ ។

**ប្រការ ៤** : អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានសិទ្ធិចុះហត្ថលេខាលើលិខិតដូចមានខាងក្រោម÷

- លិខិតដែលទាក់ទងនឹងកិច្ចការសំរបសំរួលផ្ទៃក្នុងនិងកិច្ចការរដ្ឋបាលរបស់គណៈកម្មាធិការវិនិយោគកម្ពុជា
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេស នៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងសមភាគីនានា នៅតាមបណ្ដាក្រសួង ស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេស នៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងមន្ត្រីនៃស្ថានតំណាងបរទេសនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេស នៅក្នុងទំនាក់ទងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងតំណាងក្រុមហ៊ុនវិនិយោគនានា
- លិខិតស្នើសុំ និងស្នើបន្តទិដ្ឋាការជូនវិនិយោគិន និងបុគ្គលិកបច្ចេកទេសនានា ដែលមកធ្វើការវិនិយោគ និងមកបំពេញការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការអនុញ្ញាត នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបញ្ជូនទៅក្រសួងមហាផ្ទៃពិនិត្យ និងសំរេច
- លិខិតជូនដំណឹង ឬរាល់ការសំរេច ដែលជាការឆ្លើយតបចំពោះសំណើរបស់ក្រុមហ៊ុនវិនិយោគផ្ទាល់។

**ប្រការ ៥** : ក្នុងករណីថ្នាក់ដឹកនាំណាម្នាក់អវត្តមាន ការទទួលខុសត្រូវជំនួសត្រូវបានផ្ទេរជូនថ្នាក់ដឹកនាំបន្ទាប់ ស្របតាមឋានានុក្រម និងស្របតាមភារកិច្ចទទួលខុសត្រូវរៀងៗខ្លួន ។

**ប្រការ ៦** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងគ្រប់នាយកដ្ឋាន- គ្រប់ផ្នែកចំណុះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង- ស្ថាប័នរាជរដ្ឋាភិបាល*
- *ដូចប្រការ ៧ « ដើម្បីអនុវត្ត »*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៥០...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋាន របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

### ការិយាល័យសន្តិសុខថ្នាក់កណ្តាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការអោយបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញសេចក្តីសំរេចលេខ ៤៦សសរ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ថា "ការិយាល័យសន្តិសុខថ្នាក់កណ្តាល"
- បានឃើញសេចក្តីសំរេចលេខ ៤៧សសរ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំសមាសភាពគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
- ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

## សំរេច

**ប្រការ១.**–ត្រូវបានបង្កើតលេខាធិការដ្ឋាន របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ដែលមានសមាសភាព ដូចតទៅ :

+ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហុក ឡុងឌី** អគ្គនាយកនគរបាលជាតិ ប្រធាន

+ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស សុភា** អគ្គមេបញ្ជាការរង មេបញ្ជាការ កងទ័ពជើងគោក អនុប្រធាន

+ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក

+ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជា សារិន** មេបញ្ជាការរងកងទ័ពជើងគោក សមាជិក

+ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជា តារា** នាយសេនាធិការរងចំរុះ នាយកទីចាត់ការ កលយុទ្ធ សមាជិក

+ឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ សមាជិក

+ឯកឧត្តម ឧត្តមសេនីយ៍ទោ **នេត្រ សារះឡឿន** ប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ សមាជិក

+ឯកឧត្តម ឧត្តមសេនីយ៍ទោ **ហ្វូត ឈាង** នាយកទីចាត់ការ ការិយាល័យទី៣ កងទ័ពជើងគោក សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **ឈិន ច័ន្ទពណ៌** មេបញ្ជាការរងកងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **សៅ សារិន** មេបញ្ជាការរងកងទ័ពជើងទឹក ប្រធានសេនាធិការ សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **សេស ចន្ទសេដ្ឋា** មេបញ្ជាការរងកងទ័ពជើងអាកាស ប្រធានសេនាធិការ សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **ម៉ៅ ច័ន្ទតារា** ប្រធានសេនាធិការ អគ្គនាយកដ្ឋាននគរបាលជាតិ សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម សមាជិក

+លោក ឧត្តមសេនីយ៍ត្រី **ឡៅ ស៊ុនធា** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ សមាជិក

+ឯកឧត្ដម ឧត្ដមសេនីយ៍ត្រី **ម៉ាន់ រដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រ សមាជិក

+ឯកឧត្ដម **នុត សារអាន** ទីប្រឹក្សាឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល សមាជិក

+លោក **មួន លិមហេង** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ២.**-លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ :

-ជួយប្រធានការិយាល័យសន្តិសុខថ្នាក់កណ្ដាល ក្នុងការផ្សព្វផ្សាយ និងតាមដានចាត់តាំងអនុវត្តផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ។

-ផ្សព្វផ្សាយគោលការណ៍ ផែនការផ្សេងៗរបស់ការិយាល័យសន្តិសុខថ្នាក់កណ្ដាលជូនទៅការិយាល័យសន្តិសុខថ្នាក់ក្រោម ។

-ចាត់តាំងកំលាំង ដើម្បីប្រតិបត្តិការការពារការបោះឆ្នោតតាមគំរោងផែនការដែលបានកំណត់។

-ប្រមូលផ្ដុំព័ត៌មានពីការិយាល័យសន្តិសុខថ្នាក់ក្រោម ដើម្បីរាយការណ៍ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្ដាល ។

-ពិនិត្យដោះស្រាយរាល់ការវិវាទផ្សេងៗ ឬបណ្ដឹងតវ៉ាពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោត ធ្វើរបាយការណ៍ជូនការិយាល័យសន្តិសុខថ្នាក់កណ្ដាលរៀងរាល់ ១៥ថ្ងៃម្ដង ។

-រៀបចំកម្មវិធីប្រជុំ ធ្វើលិខិតអញ្ជើញគ្រប់សមាជិកការិយាល័យសន្តិសុខថ្នាក់កណ្ដាលទាំងអស់ និងគ្រប់គ្រងឯកសារនានាតាមការសំរេចរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្ដាល ។

-ធ្វើគំរោងថវិកា ឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សំរាប់បំរើការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដាក់ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្ដាលពិនិត្យ និងសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទប្រចាំខែ ជូនការិយាល័យសន្តិសុខថ្នាក់កណ្ដាលដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣.**-លេខាធិការដ្ឋានមានសិទ្ធិបង្កើតក្រុមការងារ ដើម្បីជាជំនួយការតាមដានដឹកនាំបញ្ជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

- ប្រមូលផ្ដុំចាត់ចែងប្រើប្រាស់សំភារៈ ឧបករណ៍ និង មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់បណ្ដាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបំរើដល់ប្រតិបត្តិការរក្សាសន្តិសុខសណ្ដាប់ធ្នាប់អោយបានល្អប្រសើរក្នុងពេលដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ចាត់ចែងបើកផ្ដល់ថវិកាបំប៉នជូនកំលាំងការពារតាមគោលដៅ និង ចាត់ចែងធ្វើគំរោងបែងចែកឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូនឱ្យបានសមស្របតាមមុខសញ្ញា និងគោលដៅចាំបាច់ ។

**ប្រការ៤.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០១

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី** (sic)

**ស ខេង**

ចម្លងជូន :

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គនាយកដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលាខេត្ត-ក្រុង
- ដូចក្នុងប្រការ១
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ..៥១..សសរ

## សេចក្ដីសំរេច

ស្ដីពី

ការបង្កើតក្រុមការងារសំរាប់ពិភាក្សាលើគំរោង
បង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារមួយសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ (VOTEC) ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១_ឯកឧត្ដម | សយ សុខា | អគ្គលេខាធិការ OBSES | ប្រធាន |
| ២_ឯកឧត្ដម | សុខ ចិន្ដា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣_ឯកឧត្ដម | ក្រោញ ជ.តូនី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤_ឯកឧត្ដម | ពេជ្រ សោភ័ន | អគ្គនាយកឧត្ដមសិក្សានិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ៥_លោក | ជា វ៉ាន់ដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្ដរជាតិ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦_លោក | ខឹម ទិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៧_លោក | ចៅ យុទ្ធថា | តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨_លោក | ឃួន វ៉ាន់ន | ជំនួយការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | សមាជិក |
| ៩_លោក | ម៉ែន សុចិត្រ | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | សមាជិក |
| ១០_លោក | ហ៊ូ ឧត្តរី | ប្រធាននាយកដ្ឋានការងារនៃក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ១១_លោក | សួស យ៉ារ៉ា | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២_លោក | លន់ សុជាតិ | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ ២** : ក្រុមការងារនេះ មានភារកិច្ចដូចតទៅ ៖

_ពិនិត្យពិភាក្សាលើគំរោងសិក្សាលំអិត ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

_ទទួលពិនិត្យ និង ឆ្លើយសំណួរនានារបស់ភាគីកូរ៉េដែលទាក់ទងនឹងគំរោងបង្កើតមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈ

_រៀបចំបែបបទសំរាប់ដំណើរការគំរោង

_ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣** : ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាជិកមួយរូបអោយទទួលចាត់ចែងការងារជំនួសក្នុងពេលអវត្តមាន ។

**ប្រការ ៤** : សមាជិកទាំងអស់នៃក្រុមការងារសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបំពេញការងារតាមការបែងចែកភារកិច្ច ពីប្រធានក្រុមការងារ ។

**ប្រការ ៥** : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture,
Forestry and Fisheries

លេខ : ....354...... សសរ.កសក

# សេចក្តីសំរេច

## ស្តីពី

## ការផ្លាស់ប្តូរសមាសភាពមន្ត្រីរាជការក្នុងសេចក្តីសំរេច
## លេខ ២១៧ សសរ,កសក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៧
## លេខ ២៥០ សសរ.កសក.ចត ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៨
## និងលេខ ០៦១ សសរ.កសក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០១
## ដើម្បីអនុវត្តគំរោងបង្កើនផលិតភាពកសិកម្មក្នុងក្របខ័ណ្ឌធនាគារពិភពលោក

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នៃមូលនិធិអន្តរជាតិលេខ N0110-KH ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ១៩៩៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក
- បានឃើញអនុស្សារណៈ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៧ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចដំណើការឥណទានធនាគារពិភពលោកសំរាប់អភិវឌ្ឍន៏កសិកម្ម

- តាមសំណើលេខ ០៧៤ បុ.កសក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១ របស់នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ។
- តាមសំណើលេខ ៩៨៧ ជផ.ផត ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០១ និងលិខិតលេខ ១០៩៨ ជផ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ របស់នាយកដ្ឋានជលផល ។
- តាមមតិឯកភាពរបស់ឯកឧត្តមអ្នកប្រតិបត្តិសំរបសំរួលគំរោង ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ លើលិខិតស្នើលេខ ២០០ កសក.អគគ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០១ របស់អង្គភាពគ្រប់គ្រងគំរោង ។

## សំរេច

▱▱▱▱

<u>ប្រការ</u> ១: ចាត់តាំងលោក **អ៊ឹង រ្ទី** អនុប្រធាននាយកដ្ឋានជលផលអោយទទួលបន្ទុកជាប្រធានសំរបសំរួលគំរោងបង្កើនផលិតភាពកសិកម្មផ្នែកជលផលជំនួសលោក **ណៅ ធួក** ប្រធាននាយកដ្ឋានជលផល ដែលជាប់ភារកិច្ចមមាញឹកពុំអាចបំពេញការងាររបស់គំរោងអោយបានពេញលេញ ។

<u>ប្រការ</u> ២: ចាត់តាំងលោក **ចាន់ សារុន** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សអោយទទួលបន្ទុកជាប្រធានសំរបសំរួលគំរោងបង្កើនផលិតភាពកសិកម្មផ្នែកធនធានមនុស្សជំនួសលោក **ម៉ឹង ចាន់ឡា** ប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស ដែលជាប់ភារកិច្ចមមាញឹកពុំអាចបំពេញការងាររបស់គំរោងអោយបានពេញលេញ ។

<u>ប្រការ</u> ៣: ក- ចាត់តាំងលោក **ស្វួច ស៊ីថា** មន្ត្រីរាជការការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលអោយទទួលបន្ទុកតាមដាន និង វាយតំលៃគំរោងជំនួសលោក **ខួន សាវីធួន** អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ដែលពុំមានពេលវេលាអាចមកបំពេញការងារជូនគំរោងបាន ។

ខ- ចាត់តាំងលោក **កែម ខឿន** មន្ត្រីរាជការការិយាល័យវារីវប្បកម្មនៃនាយកដ្ឋានជលផល អោយទទួលបន្ទុកជាជំនួយការផ្នែកលទ្ធកម្មជំនួសលោក **ស៊ុន សុខចេង** មន្ត្រីនាយកដ្ឋានគ្រឿងយន្តកសិកម្ម ដែលត្រូវបានចាត់តាំងអោយទៅបំរើការងារជាមន្ត្រីលទ្ធកម្មនៃគំរោងឥណទានកម្មវិធីធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445 CAM (SF) ។

គ- ចាត់តាំងកញ្ញា **ឯក សម្ជនា** មន្ត្រីរាជការការិយាល័យដំណាំឧស្សាហកម្មនៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម អោយទទួលបន្ទុកជាលេខាជំនួសលោកស្រី **ទាយ ឈុម** មន្ត្រីរាជការនាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស ដែលត្រូវបានចាត់តាំងអោយទៅបំរើការងារជាមន្ត្រីជំនួយការរដ្ឋបាលនៃគំរោងឥណទានកម្មវិធីធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445 CAM (SF) ។

**ប្រការ ៤ :** ចាត់តាំងលោក **មាឡ សេរីវុឌ្ឍ** មន្ត្រីបំរើការនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងផលិតកូនត្រីពូជនៅបាទី អោយទទួលបន្ទុកជាជំនួយការជំនួសលោក **អ៊ុយ សឈ** អនុប្រធានស្ថានីយ៍បាទី ដែលបានទទួលមរណៈភាពកាលពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០១ ។

**ប្រការ ៥ :** មន្ត្រីរាជការទាំងអស់ ដែលទើបត្រូវបានចាត់តាំងជំនួសក្នុងប្រការ ១ ប្រការ ២ ប្រការ ៣ និងប្រការ ៤ ខាងលើត្រូវអនុវត្តការងារតាមភារកិច្ចរៀង១ខ្លួន ដូចខ្លឹមសារយោងកំណត់ស្រាប់ ។

**ប្រការ ៦ :** សេចក្តីសំរេចលេខ ២១៧ សសរ.កសក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៧ និង លេខ ២៥០ សសរ.កសក.ចត ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៨ ដែលមានខ្លឹមសារផ្ទុយនឹងខ្លឹមសារនៃសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយកក្រសួង នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានជលផល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានកសិកម្ម ... ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល គ្រប់អង្គភាពពាក់ពន្ធ័ និងសាមីជនត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៧ ខែ ៨ ឆ្នាំ ២០០១

រដ្ឋមន្ត្រី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  " ដើម្បីជូនជ្រាប "
- ដូចមានចែងក្នុងប្រការ ៧
  " ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry Mines and Energy

№ ៥៣១ អឧថ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១

## ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការធ្វើអាជីវកម្ម ថ្មសំរាប់ដុតធ្វើកំបោរស ថ្មដុស និង ថ្មលាង នៅតំបន់ភ្នំដុប ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត រវាង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង លោកស្រី នាក់ យន់ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១ ។

## សំរេច

**ប្រការ១** : អនុញ្ញាតអោយលោកស្រី នាក់ យន់ មានអាស័យដ្ឋានភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកកំពត ខេត្តកំពត ធ្វើអាជីវកម្ម ថ្មសំរាប់ដុតធ្វើកំបោរស និង ថ្មដុស ថ្មលាង នៅតំបន់ភ្នំដុប ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត លើផ្ទៃដី ០១(មួយ)ហិកតា មានកូអ័រដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោណេ | ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|---|---|---|
| A | 4 42 $^{90}$ | 11 68 $^{80}$ | C | 4 43 $^{00}$ | 11 68 $^{70}$ |
| B | 4 43 $^{00}$ | 11 68 $^{80}$ | D | 4 42 $^{90}$ | 11 68 $^{70}$ |

**ប្រការ២** : លោកស្រី នាក់ យន់ ត្រូវដំណើរការអាជីវកម្ម ថ្មសំរាប់ដុតធ្វើកំបោរស ថ្មដុស និង ថ្មលាង នៅតំបន់ភ្នំដុប ទៅតាមទំហំផ្ទៃដី ដែលបានកំណត់ខាងលើ និង :

- រាយការណ៍ប្រចាំខែស្តីពី បរិមាណដែលផលិតបាន និង បង់ថ្លៃវត្ថុធាតុដើម ថ្មសំរាប់ដុតធ្វើកំបោរស ថ្មដុស និង ថ្មលាង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពត ។
- ធានាការអនុវត្តន៍តាមលក្ខណៈបច្ចេកទេសអាជីវកម្មរ៉ែ និង ធានាការការពារបរិស្ថានអោយបាន ត្រឹមត្រូវតាមច្បាប់ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារៈ (៨៥៥) ២៣-៤២៨ ២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh (Cambodia) Tel / Fax (855) 23-428 263

**ប្រការ៣** : ពេលជួបប្រទះរ៉ែផ្សេងៗត្រូវរាយការណ៍មកក្រសួងជាបន្ទាន់ ។ បើប្រព្រឹត្តិល្មើសដោយយកទីតាំងខាងលើធ្វើអាជីវកម្មថ្មសំភារៈសំណង់ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត និង មានការពិន័យ ។

**ប្រការ៤** : ប្រកាសនេះមានតម្លៃរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់៣០ថ្ងៃ លោកស្រី នាក់ យន់ ត្រូវដាក់ពាក្យសុំអនុញ្ញាតបន្ត ។

**ប្រការ៥** : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកំពត និង លោកស្រី នាក់ យន់ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៦** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន**

- ទីស្តីការគណរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- អភិបាលខេត្តកំពត
- អភិបាលស្រុកកំពង់ត្រាច
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១-១១៥ ប្រក

# ប្រកាស

## ស្តីពី

## ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៣៩៨/ ៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ ៧០០-០៥ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការ ផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារ ឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ ៧០០-០៦ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំរេច

**ប្រការ ១.**

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគម ចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួន អោយបានស្របតាមខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ ២.**

ការប្រាក់ចំពោះឥណទានដែលបានផ្តល់អោយតាមខ្លឹមសារនៃប្រកាសនេះត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយ បានន័យថា ការប្រាក់លើឥណទានសំរាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ ។

**ប្រការ ៣.-**

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជន ត្រូវមានបង្ហាញតារាងពីការសងរំលោះឥណទាន ។

**ប្រការ ៤.-**

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០១

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៦ " ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ

**ចម្លងជូន**

-គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាពត៌មាន"
-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

malay/ongoingjob/prakas calculation of interest rate to MFI

Rith / ... 2

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ... /២០០១

ភ្នំពេញ,ថ្ងៃទី ១០ ខែ ... ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈ នស.រកម.០១.៩៦.០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦ នស ៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល
- បានឃើញលិខិតលេខ ៣៨៣ មស.ក្រខ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងកំណត់ហេតុប្រជុំចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១**- ត្រូវបានបង្កើត គណៈកម្មការមេប្រយោគដើម្បីដឹកនាំគ្រប់គ្រង គណៈកម្មការ ក្នុងការប្រឡងជ្រើសរើសនិស្សិត,សិស្ស ឱ្យចូលក្របខ័ណ្ឌក្រសួងយុត្តិធម៌ និងបូកសារុបវាយតម្លៃ ប្រកាសលទ្ធផលប្រឡង ។

**ប្រការ ២**- សមាសភាព នៃគណៈកម្មការមេប្រយោគមាន :

| | | |
|---|---|---|
| ១- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ប្រធាន |
| ២- ឯកឧត្តម ស៊ុយ នូ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង | | សមាជិក |
| ៥- ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ទទួលបន្ទុកកិច្ចការបុគ្គលិក និងបណ្តុះបណ្តាល | | សមាជិក |

**ប្រការ ៣**- គណៈកម្មការនានា ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យ របស់គណៈកម្មការមេប្រយោគ មានដូចតទៅ :

**I- គណៈកម្មការកណ្តាល**

| | | |
|---|---|---|
| ១-ឯកឧត្តម ប៉ុក ម៉ាន់នី | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-លោក ស៊ឹម ឫទ្ធីសែន | ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល | សមាជិក |
| ៣-លោក អ៊ិត រ៉ាឌី | អគ្គាធិការរង | សមាជិក |
| ៤-លោក កែវ សុផល | អនុប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល | សមាជិក |
| ៥-លោក គុង ពារ | ប្រធាននាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក ទី សុវិនថាល់ | មន្ត្រីច្បាប់ | សមាជិក |
| ៧-លោកស្រី ចាន់ សុទ្ធារី | មន្ត្រីច្បាប់ | សមាជិក |

II- គណៈកម្មការអប្បមាន

| | |
|---|---|
| ១_លោក ងួន សេង អនុប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល | ប្រធាន |
| ២_លោក នាង ស៊ីណារ៉ុឌ្ឍនៈ មន្ត្រីច្បាប់ | សមាជិក |
| ៣_លោក យុត យន់ អនុប្រធានការិយាល័យរដ្ឋបាល | សមាជិក |
| ៤_លោក លាង សូតិ មន្ត្រីច្បាប់ | សមាជិក |
| ៥_លោក គង់ សារឿន ក្រឡាបញ្ជី | សមាជិក |

III- គណៈកម្មការអនុរក្ស

| | |
|---|---|
| ១_លោក ចាក់ ចន្ទសំបូរ ប្រធានការិយាល័យអយ្យការ | ប្រធាន |
| ២_លោកស្រី សួរ ដានី ក្រឡាបញ្ជី | សមាជិក |
| ៣_កញ្ញា សែម សុទ្ធារី ក្រឡាបញ្ជី | សមាជិក |
| ៤_ កញ្ញា ហួត វាសនា បុគ្គលិក | សមាជិក |
| ៥_ កញ្ញា សៀ ចាន់វាសនា | សមាជិក |
| ៦_ កញ្ញា ប៉ែន សុមេធា | សមាជិក |
| ៧_ លោក ស៊ិន វិសាល | សមាជិក |
| ៨_ លោក ទៀង សុថា | សមាជិក |
| ៩_ លោក ប៊ូ ប៊ុនហាង | សមាជិក |
| ១០_លោក សួស សំអាត | សមាជិក |
| ១១_លោក ព្រំ ស៊ីថា | សមាជិក |
| ១២_កញ្ញា សរ ច័ន្ទរ៉ាត | សមាជិក |
| ១៣_កញ្ញា ផាន់ ច័ន្ទលី | សមាជិក |
| ១៤_កញ្ញា ស្រេង សូយ៉េត | សមាជិក |
| ១៥_លោក លិន សីលា | សមាជិក |
| ១៦_លោក វ៉ា ឈួន | សមាជិក |
| ១៧_លោក ចាន់ ណា | សមាជិក |
| ១៨_លោក ប៉ែន សារ៉ាត | សមាជិក |
| ១៩_កញ្ញា ម៉ៅ ភិរុណ | សមាជិក |
| ២០_លោក ពៅ ប៊ុនធឿន | សមាជិក |

IV- ក្រុមលេខាធិការ

| | |
|---|---|
| ១_លោក ទិត សារឿន អនុប្រធានការិយាល័យបុគ្គលិក | ប្រធាន |
| ២_លោក ភោគ ម៉ារ៉ា ក្រឡាបញ្ជី | សមាជិក |
| ៣_លោក សួង ម៉េងហុង អនុប្រធានការិយាល័យភស្តុភា | សមាជិក |
| ៤_លោក ចេង គីមហ៊ាង ក្រឡាបញ្ជី | សមាជិក |
| ៥_លោក គីម សំអាត ក្រឡាបញ្ជី | សមាជិក |

V- គណៈកម្មការគណនេយ្យ

| | |
|---|---|
| ១_លោក សុខ សារុន អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | ប្រធាន |
| ២_លោកស្រី សោម សារ៉ាន់ ក្រឡាបញ្ជី | សមាជិក |
| ៣_លោក សំ វេងសៀង ក្រឡាបញ្ជី | សមាជិក./ |

VI- គណៈកម្មការសន្តិសុខ

១_លោក តុង ពារ ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ប្រធាន

និង ប៉ូលីស ០៧ រូប ជាសមាជិក

ប្រការ ៤_ គណៈកម្មការចេញ និងកែវិញ្ញាសារ ព្រមទាំងគណៈកម្មការចុះលេខសំងាត់ ត្រូវចាត់តាំងដោយប្រធានគណៈកម្មការមេប្រយោគ ។

ប្រការ ៥_ គ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ឯកឧត្តម,លោក,លោកស្រី ដែលមានឈ្មោះក្នុងប្រកាសនេះត្រូវអនុវត្តន៍ភារកិច្ចរៀង ៗ ខ្លួនឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៥

"ដើម្បីជូនជ្រាប និងអនុវត្ត"

- កាលប្បវត្តិ_ឯកសារ

រដ្ឋមន្ត្រី

អ៊ុក_វិធុន

Rith / ... 5

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ... /២០០១

ភ្នំពេញ,ថ្ងៃទី ... ខែ ... ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈ នស.រកម.០១.៩៦.០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦ នស ៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល
- បានឃើញប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ទីស្តីការ ក្រសួងយុត្តិធម៌
- យោងកំណត់ហេតុប្រជុំចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

## សំរេច

ប្រការ ១- ត្រូវបានបង្កើត អនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ និង អនុគណៈកម្មការហិរញ្ញវត្ថុ ក្នុងការប្រឡងជ្រើសរើសនិស្សិត.សិស្ស ឱ្យចូលក្របខ័ណ្ឌក្រសួងយុត្តិធម៌ ដែលសមាសភាពដូចខាងក្រោម :

I- **អនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ**

| | |
|---|---|
| ១-លោកស្រី ជា លាង អនុប្រធានការិយាល័យបណ្តុះបណ្តាល | ប្រធាន |
| ២-លោក អិន វ៉ាន់វិបុល អនុប្រធានការិយាល័យបណ្តុះបណ្តាល | សមាជិក |
| ៣-លោក ប៉ែន សារ៉ាត អនុប្រធានការិយាល័យបុគ្គលិក | សមាជិក |
| ៤-លោក ទិត សារឿន អនុប្រធានការិយាល័យបុគ្គលិក | សមាជិក |
| ៦-លោកស្រី សួរ ដានី ក្រឡាបញ្ជី | សមាជិក |

អនុគណៈកម្មការនេះមានភារកិច្ចទទួលខុសត្រូវ ក្នុងការរៀបចំឯកសារផ្សេងៗ ដែលទាក់ទងការប្រឡង និងទទួលពាក្យសុំចុះឈ្មោះប្រឡង ទទួលពិនិត្យរៀបចំទុកដាក់ ពាក្យសុំចុះឈ្មោះប្រឡង និងធ្វើបញ្ជីឈ្មោះនិស្សិត.សិស្ស ទៅតាមបន្ទប់ប្រឡង ។

II- **អនុគណៈកម្មការហិរញ្ញវត្ថុ**

| | |
|---|---|
| ១-លោក សុខ សារុន អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | ប្រធាន |
| ២-លោកស្រី សោមសារ៉ាន់ ក្រឡាបញ្ជី | សមាជិក |
| ៣-លោក សំ វេងសៀង ក្រឡាបញ្ជី | សមាជិក |

អនុគណៈកម្មការនេះមានភារកិច្ច ដោះស្រាយ និងផ្គត់ផ្គង់សំភារៈ ថវិកា និងមធ្យោបាយចាំបាច់ផ្សេងៗ សំរាប់បំរើការងារប្រឡងដោយធ្វើការទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរួមចំណែកធ្វើឱ្យការ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ ខែ_____ ឆ្នាំ_____

Rith / rith 6

ប្រឡងមានដំណើការល្អទទួលបានជោគជ័យ ។

<u>ប្រការ</u> ២_ អនុគណៈម្មការទាំងពីរខាងលើនេះ ត្រូវអនុវត្តភារកិច្ចតាមការណែនាំពី គណៈកម្មការមេប្រយោជ ។

<u>ប្រការ</u> ៣_ អនុគណៈម្មការទាំងពីរខាងលើ និងសាម៉ីខ្លួនដែលមានឈ្មោះក្នុងប្រកាសនេះ ត្រូវអនុវត្តន៍ភារកិច្ចរៀង ៗ ខ្លួន ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៣
  <u>"ដើម្បីជូនជ្រាប និងអនុវត្ត "</u>
- <u>កាលប្បវត្តិ_ឯកសារ</u>

រដ្ឋមន្ត្រី

អ៊ុក_រ៉ាប៊ុន